លី-ធាមតេង

Mr Watanabe

# សរសេរតាមសូត្រ

## ~ ពន្យល់ ~

សំរាប់

## សិស្ស - គ្រូ

ក្នុងការប្រឡងចូលថ្នាក់ទី ៦ មធ្យមសិក្សា



បណ្ណាគារ សេង-ងួនហួត ភ្នំពេញ

CA9

លី · ជាមតេង

# សរសេរតាមសូត្រ

## ពន្យល់

# DICTEE EXPLIQUEE

សំរាប់

## សិស្ស-គ្រូ

ក្នុងការប្រឡងចូលថ្នាក់ទី ៦ មធ្យមសិក្សា

ចេញផ្សាយពី

បណ្ណាគារ

សែង · ងួន · ហ៊ួ

លេខ ៦៣ វិថីព្រះបាទចន្ទរាជា

ភ្នំពេញ

១៩៥៨

# អារម្ភកថា

សរសេរតាមសូត្រ ឬ អនុវាក្យ ជាកិច្ចការពិសេសមួយសំរាប់អ្នកសិក្សាគ្រប់ថ្នាក់ ។ គឺនៅក្នុងមុខវិជ្ជានេះហើយ ដែលណែនាំសិស្សឲ្យចេះសរសេរបានត្រឹមត្រូវ ទាំងអក្ខរាវិរុទ្ធរបស់ពាក្យ និងរបៀបត្រឹមត្រូវតាមវេយ្យាករណ៍ ។

នៅក្នុងសៀវភៅនេះ ខ្ញុំបានជ្រើសរើសអត្ថបទប្លែក ៗ ពីអ្នកនិពន្ធដទៃខ្លះ និងសរសេរឡើងដោយខ្លួនឯងខ្លះ ដែលសុទ្ធតែមានពាក្យពេចន៍គ្រប់គ្រាន់ជួយផ្តល់ប្រយោជន៍ ក្នុងការរៀនសូត្រដល់បណ្តាសិស្សនៅថ្នាក់ទី ៦ និង នៅថ្នាក់ឧត្តមដ្ឋានដែលត្រូវប្រឡងប្រៀបបន្តវិជ្ជ ទៅមធ្យមសិក្សាទៀត ។ នៅខាងចុងអត្ថបទនីមួយ ៗ ខ្ញុំបានធ្វើជាសេចក្តីពន្យល់ពីអត្ថន័យពាក្យមួយម៉ាត់ ៗ , ពីអក្ខរាវិរុទ្ធរបស់ពាក្យ និងវាក្យស័ព្ទដែលសិស្សត្រូវការចំណាំទុក កុំឲ្យមានការភ័ន្តច្រឡំតទៅ ។

ពិតមែនតែក្នុងសៀវភៅនេះ មិនមានអត្ថបទអនុពាក្យច្រើន ដល់ទៅរាប់រយ តែខ្ញុំសង្ឃឹមថា ក៏គង់បានជាជំនួយមួយយ៉ាង សំខាន់របស់អ្នកត្រូវការជាមិនខាន ។

ទីបំផុត ខ្ញុំសូមថ្លែងសេចក្ដីគោរពយ៉ាងសុទ្ធចិត្តចំពោះ អស់លោកអ្នកនិពន្ធទាំងឡាយ ដែលខ្ញុំបានដកស្រង់យក ស្នាដៃរបស់លោកមកដាក់ក្នុងសៀវភៅនេះ ។

ភ្នំពេញ, ថ្ងៃទី២៣ មករា ១៩៥៨

អ្នកនិពន្ធ

# ១ - បើកសិក្សាកាល

ថ្ងៃនេះ, បើគេសង្កេតពីចម្ងាយមក គេឃើញមានមនុស្សអ៊ូអរនៅមុខសាលារៀនប្លែកពីធម្មតា ។ គឺជាបវេសនកាល ។ សិស្សតូចៗប្រញាប់ដោយសំលៀកបំពាក់ស្អាតៗ កាន់សៀវភៅថ្មីៗនៅដៃ ហើយដើរតម្រង់ចូលទៅគ្រឹះស្ថានសិក្សារបស់ខ្លួន ។ នៅក្នុងសួនពីមុខសាលាដែលមានផ្កាពណ៌ផ្សេងៗជាលំអ មានសិស្សច្រើនរូបឈរនិយាយគ្នាសើចក្អាកក្អាយ ព្រោះគេបែកគ្នាអស់រយៈវេលាជាងពីរខែហើយ ។ សូរនិយាយនេះ បង្កើតបានជាសព្ទច្រហឹងអឹងកង បីដូចហ្វូងឃ្មុំកំពុងហើរជុំវិញសំបុក ។

ចលនារស់រវើកនេះ កើតមានចំពោះតែសិស្សចាស់ៗទេ ចំណែកអ្នកទើបតែមកចូលរៀនដំបូងក្នុងថ្ងៃនេះវិញ ពុំសូវរីករាយដូចគេសោះ ដ្បិតនៅក្នុងចិត្តគេ ចេះតែមានសេចក្ដីបារម្ភជានិច្ច ដោយគេពុំទាន់ស្គាល់អ្នកណាជាមិត្តនៅ

ឡើយ ។ ឯពពួកគ្រូ តែងចុះឡើងរៀបចំធ្វើពិធីគោរពទង់ជាតិ ។ គេឈរតម្រៀបគ្នាជាជួរ ៗ ដោយកិច្ចបញ្ជានៃគ្រូម្នាក់ សិស្សទាំងនោះបន្លឺឡើងនូវបទនគររាជយ៉ាងគ្រលួច នៅពេលដែលទង់ជាតិ បានបង្ហូតឡើងខ្ពស់ត្រដែតនៅលើចុងដងទង់ ហើយកាច់កែវក្រើតតាមចង្វាក់ខ្យល់ព្រះពាយ ៗ របកិច្ចនេះហើយ គេដើរទាំងជួរ ៗ តម្រង់ទៅថ្នាក់រៀនរៀង ៗ ខ្លួន ។

ឱកាសនេះ គួរចាត់ទុកជាឱកាសមួយយ៉ាងឧឡារិក នឹងជាអនុស្សាវរីយ៍ របស់សិស្សគ្រប់រូបក្នុងវេលាដែលសិស្ស នឹងគ្រូបានជួបមុខគ្នាជាថ្មីទៀត ។

លី - ណាមតេង

ក– ពន្យល់ពាក្យ

បវេសនកាល : ថ្ងៃចូលរៀនដំបូង, (La rentée) ។

គ្រឹះស្ថានសិក្សា : ផ្ទះ ឬ លំនៅជាកន្លែងរៀនសូត្រ ។

រយៈវេលា : រវាងវេលា (la durée) ។

ចលនា : ការកំរើក (mouvement) ។

នគររាជ : ឈ្មោះភ្លេងប្រចាំជាតិរបស់ខ្មែរយើង ។

យ៉ាងឧឡារិក : យ៉ាងអឹកធឹក, យ៉ាងកិត្តិយស ។

អនុស្សាវរីយ៍ : ជាទីរលឹកមិនភ្លេច (souvenir) ។

ខ– អក្ខរាវិរុទ្ធ

អ៊ូអរ (មាន រ នៅចុង)

ប្លែក (អក្សរ ប មិនមែនអក្សរ ផ ទេ)

លំអ (ឥតមាន រ ទេ)

រយៈវេលា (ត្រូវមានយុគលពិន្ទុពីមុខអក្សរ យ)

ហើរ (មាន រ នៅចុង)

គ– ពាក្យស័ព្ទ

លំអ គុ. (ផ្ទះនេះមានគ្រឿងលំអជាច្រើន)

អំណរ ន. (ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក)

កំពុង កិ. (ខ្ញុំកំពុងធ្វើការ)

កំពង់ ន. (គេទៅទិញត្រីឯមាត់កំពង់)

បារម្ភ កិ. (ខ្ញុំបារម្ភណាស់ពីរឿងនេះ)

អារម្មណ៍ ន. (គេអង្គុយបណ្តែតអារម្មណ៍)

ជួរ ន. (ដើមស្វាយតម្រៀបគ្នាជាជួរ)

ឆ្លូ គុ. (ក្មេងនេះមានឫកពាឆ្លូណាស់)

ចង្វាក់ ន. (ច្រៀងឲ្យត្រូវតាមចង្វាក់ភ្លេង)

សង្វាក់ ន. (សង្វាក់ជាម្ហូបពិសេសនៅខេត្តបាត់ដំបង)

## ២- អ្នកតាដង្កោតាឌិល

នៅពេលជិតថ្ងៃត្រង់ កងរទេះបានបរដល់ដំបន់មួយ ហៅថាដង្កោតាឌិល ដែលជាទីខ្ពស់មួយ ទឹករដូវវស្សាមិនដែលលិចទេ ។ បានជាអ្នកផងហៅថា ទួលដង្កោតាឌិល

ដូច្នេះ ព្រោះទួលនេះមានដើមដង្កោមួយធំខ្មៅដូចធ្យូង តែកំបុតឥតចុងដោយរន្ទះបាញ់ផ្ដាច់ជាយូរមកហើយ ។ រុក្ខជាតិនេះមានស្លឹកនៅតែគ្រប់ប្រគាបប៉ុណ្ណោះ ។ នៅភ្ជាប់នឹងដើមដង្កោនេះ មានដើមអំពិលមួយធំណាស់ដែរ ដែលបែកមែកសាខាហាក់ដូចជាគ្របបាំង កុំឲ្យកូនខ្ទមតូចមួយដែលនៅឯបនឹងគល់ ត្រូវកំដៅព្រះអាទិត្យឡើយ ។ នៅក្នុងខ្ទម មានបដិមាមួយធ្វើពីថ្មខ្មៅប្រផេះ ។ រូបនេះមានបបូរមាត់ញ្ញាក់សម្យែស ហើយមានផ្ទាំងជាតិ រុំព័ទ្ធជាក្រមា ។

រូបចម្លាក់នេះ ជារូបអ្នកតាដង្កោតានិលដែលមានឫទ្ធានុភាពខ្លាំងពូកែណាស់ ។ អ្នកដំណើររទេះ កាលបើបានដល់ទួលនេះហើយ តោងខ្មីឃ្មាតកាច់មែកឈើ, ប្រួចស្រា, សែនបាយទឹក, ចំណីចំណុក ដើម្បីសូមលាភ, សូមជ័យពីលោកអ្នកតា ។

នូ - ហាប

## ក- ពន្យល់ពាក្យ

កង់រទេះ : ហ៊ុងរទេះ, រទេះមួយហ៊ុង ។

មែកសាខា : មែកសន្ធឹងទៅសងខាងមានម្លប់ត្រជាក់ ។

បដិមា : រូបសំណាក, រូបចម្លាក់ដំណាងអ្វីមួយ ។

ធ្លាក់សម្យែស : ធ្លាក់ស្តែស, ធ្លាក់ចេញគេកលរបូត ។

ផ្ទាំងវាតី : ផ្ទាំងក្រណាត់ក្រហមពណ៌ឈាម ។

បុប្ផានុភាព : បេស្តាបារមី, បុប្ផអំណាច ។

### ១- អក្ខរាវិរុទ្ធ

ប្រគាប (សរសេរ គ ដាក់ស្រៈ អា)

ភ្ជាប់ (សរសេរ ភ ដាក់ជើង ជ )

ឯប (សរសេរអក្សរ ឯ ស្រៈពេញតួ )

បបូរ (មាន រ នៅចុង )

ប្រួប (សរសេរ ប មិនមែន ជ ទេ )

លាភ ( ត្រូវប្រកបនឹងអក្សរ ភ )

ជ័យ ( ដាក់សំយោគសញ្ញាលើ ជ )

គ– វាក្យស័ព្ទ

លិច កិ. ( ទឹកលិចពេញព្រៃ. ថ្ងៃលិចចុះ )

លេច កិ. ( លេចឃើញ. លេចឡើង )

លាភ ន. ( ខ្ញុំមានលាភបានចំណេញប្រាក់ ១ ម៉ឺន )

លាប កិ. ( ជាងលាបផ្ទះល្អ )

---

## ៣ – ប្រាសាទអង្គរវត្ត

អង្គរវត្តជាប្រាសាទមួយល្អជាងគេ បណ្ដា (*parmi*) ប្រាសាទទាំងឡាយនៅអង្គរ ។ គេកសាងក្នុងសម័យនៃវិទ្យាសាស្ត្រ (*science*) កំពុងចំរើនបរិបូណ៌ (*suffisamment*) ព្រោះមានទ្រង់ទ្រាយ (*forme*) ល្អ នឹងទ្រង់សក្តិសមនៃភាពពង់ លេចស្រស់ឡើងក្នុងកាលគេចូលទៅជិត ហើយគេអាចយកទៅទុកគ្នានឹងវិស្វកម្ម (*Ingénieur*) នៃប្រទេសអស្ចារ្យបាន ។

ប្រាសាទនគរវត្តនេះ ព្រះបាទសូរ្យវរ្ម័នទី ២ ស្ដេចសាងក្នុងរវាងសតវត្សទី ១៧ នៃពុទ្ធសករាជ ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុ, លុះដល់ស្ដេចទិវង្គតទៅ Mort គេថ្វាយព្រះនាមព្រះអង្គថា "ព្រះបរមវិស្ណុលោក" ។

ស្ពានថ្មធំមួយ ចូលពីទិសបស្ចិម កាត់ក្លងស្រះពោក្ខរណី រហូតទៅដល់ទ្វារធំខាងលិច នៃប្រាសាទនេះ ដ៏មានបង្កាន់ដៃនាគ ប្រកបដោយសីហៈធំសំបើម, ងើយមុខស្មើន, តែឥឡូវនេះបាក់បែកស្ទើរតែអស់ហើយ ។ កាលណាគេចូលទៅដល់ក្លោងទ្វារធំខាងលិចនេះ ទ្រង់ទ្រាយរុងរឿងឆើតឆាយ, ទ្រង់ទ្រាយមានឫទ្ធិតេជៈនៃប្រាសាទនេះ អាចធ្វើឲ្យអ្នកដំណើរស្ញប់ស្ញែងក្នុងចិត្ត ។

ប៉ាង - ខាត់

## ក-ពន្យល់ពាក្យ

វិទ្យាសាស្ត្រ : ក្បួនច្បាប់នៃវិជ្ជា, ការត្រិះរិះវិជ្ជា (science) ។

វិស្វកម្ម : ការងារទូទៅ, កំពើគ្រប់យ៉ាងខាងជំនាង ។

ប្រទេសអស្តង្គត : ពួកប្រទេសបែកខាងលិច (Occidental) ។

សតវត្ស ឬ សតវត្សរ៍ : រយៈកាល ១០០ ឆ្នាំ (siècle) ។

ព្រះវិស្ណុ : ឈ្មោះទេព្តាមួយអង្គខាងសាសនាព្រាហ្មណ៍ ។

ទិវង្គត : សោយវិលាល័យ, សុគត ។

បស្ចិម : ទិសខាងលិច ។

ស្រះបោក្ខរណី : ស្រះដែលមានដាំឈូក ។

សីហៈ : សត្វសិង្ហ (រូបសត្វសិង្ហ) ។

ឫទ្ធិតេជៈ : បុណ្យបារមី, ឫទ្ធិអំណាច ។

ខ- អក្ខរាវិរុទ្ធ

បណ្ដា (ឥតមាន រ ទេ)

នាគ (សរសេរប្រកបនឹង គ)

ស្មើរ (មាន រ ឯស្មើគ្មាន រ ទេ)

ក្លោងទ្វារ (សរសេរ ក ដាក់ជើង ល)

តេជះ (សរសេរ ត ដាក់ស្រៈ អេ)

គ- វាក្យស័ព្ទ

ក កិ. (គេកសាងសាលាថ្មីមួយ)

ក៏ និ. (ខ្ញុំក៏មានលុយ គេក៏មានលុយ)

ករ ន. (អមាត្យលើកករប្រណម្យព្រះរាជា)

សក្ដិ ន. (សក្ដិសមល្អ, អ្នកមានយសសក្ដិ)

សាក់ កិ. (ខ្មែរខ្លះសាក់ពេញទាំងខ្លួនដោយ័ន្តគាថា)

ស័ក ន. (ឆ្នាំនេះជាឆ្នាំរកានព្វស័ក)

# ៤- វិធីព្រះអង្គអេង

ព្រះអង្គអេង ! ព្រះអង្គអេង ! ជាឈ្មោះវិធីមួយដែលខ្ញុំចាំបានយ៉ាងស្អាត់ ៗ វិធីនេះមានមនុស្សគេះកំលើសវិធីនានាក្នុងរាជធានី ៗ នៅលើខឿនផ្លូវទាំងសងខាងមានប្រុស-ស្រីក្មេង-ចាស់សញ្ជរទៅ-មកឥតឈប់ ៗ បើគេគយគន់ពីចម្ងាយមក ឃើញតែក្បាលមនុស្សខ្មៅម៉ឺ ហើយមានសភាពមិនរាបស្មើ ប៉ុន្ដូចជារលកទឹកគគ្រាំគគ្រេងក្នុងផ្ទៃជល-ធារ ៗ ហ្វូងនារីដែលតុបតែងប្រាណយ៉ាងស្រស់បំព្រង, បញ្ចេញគន្ធពិដោរក្រអូបសាយពីពងកាយ ដើរខ្ទេងខ្ទាត់កែទិញគ្រឿងប្រណីត មានម្សៅទឹកទឹកអប់ជាដើម ៗ

ចំណែកហ្វូងបុរស ក៏សំអិតសំអាងកាយមិនឲ្យចាញ់ប្រៀបនារីទាំងនោះដែរ ៗ គេដើរបញ្ចេញទឹកមុខស្រស់ប្រិមប្រិយ៍សឲ្យឃើញថាជាអាជ្ញាដនក្នុងសតវត្សនេះ ៗ នៅចំកណ្ដាលវិធីដែលបែកចេញពីគ្នាជាបួន មានភ្នាក់ងារអាក្សា

ឈរនៅចាំធ្វើបញ្ជាលើចរាចរណ៍ ដើម្បីជៀសវាងកុំឲ្យមាន
circulation
គ្រោះថ្នាក់ដល់ប្រជាជន និងរថយន្តនានាឲ្យបត់ទៅតាមផ្លូវឯកទិស ។

វិថីព្រះអង្គអេង គួរចាត់ទុកជាវិថីមួយដ៏ល្អឯកក្នុងរាជធានីយើង ប៉ុន្តែបើសង្កេតឲ្យច្បាស់លាស់ទៅ ឃើញច្រើនតែជនបរទេស ដែលនៅតាំងទីលក់ដូរតាមរបៀងផ្ទះនិងលើខឿនវិថីនេះ ។ ឯបណ្តាជនខ្មែរយើងច្រើនតាំងខ្លួនជាអ្នកដើរទិញ សព្វកាលសព្វវេលា ។

លី - ណាមតេង

ក- ពន្យល់ពាក្យ

វិថី : ផ្លូវធំ ៗ ដែលនៅក្នុងទីក្រុង (la rue) ។

រាជធានី : ទីក្រុងធំ, ក្រុងដែលស្តេចគង់នៅ (la capitale) ។

សញ្ចារ : ដើរទៅ-មក, ធ្វើដំណើរតាមផ្លូវ ។

ជលចារ : ផ្លូវទឹក, ទន្លេឬសមុទ្រ ។

គន្ធពិដោរ : ក្លិនក្រអូប ។

គ្រឿងប្រណីត : គ្រឿងទំនើបដ៏មានដម្លៃ (luxe) ។

អារ្យជន : ជនស៊ីវិល័យ, មនុស្សចំរើន (Civilisateur) ។

អារក្ខា : អ្នករក្សា, អ្នកត្រួតត្រាឲ្យសុខ (Police) ។

ធ្វើបញ្ជា : ធ្វើសេចក្ដីបង្គាប់ (Commander) ។

ចរាចរណ៍ : ការដើរ, ការត្រាច់ទៅ-មក (Circulation) ។

ឯកទិស : ទិសតែមួយដែលតម្រូវឲ្យទៅ (Sens unique) ។

ជនបរទេស : អ្នកប្រទេសដទៃ (étranger) ។

បណ្ដាជន : ចំណោមមនុស្សនៅក្នុងប្រទេស (population) ។

១- អក្ខរាវិរុទ្ធ

កុះកុំ (កុំសរសេរ កុសកុំ)

នានា (កុំសរសេរនា ៗ ឲ្យសោះ)

មីរ (សរសេរមាន រ នៅខាងចុង)

ផលផារ (កុំសរសេរ ផល់ផា)

ប្រណីត (សរសេរស្រះ អី លើ ណ)

ប្រឹមប្រិយ៍ (កុំសរសេរ ប្រិមប្រិ)

ទិស (កុំសរសេរ ទឹស)

គ- វាក្យស័ព្ទ

ឥដ្ឋ ន. (ផ្ទះឥដ្ឋ. កំពែងឥដ្ឋ)

ឥត និ (និយាយនេះ ឥតបានជាការទេ)

ស កិ. (សឡូឃើញនូវសេចក្ដីក្លាហានរបស់ខ្មែរ)

ស កិ. (ពូព្រហ្មសត្រីក្នុងបឹង)

ស ន. (ក្រដាសសង្ខូបសំឡី)

សរ ន. (ព្រះរាមថ្លែងសរបាញ់យក្ស)

---

## ៥ - ផ្ទះកំណើត

ផ្ទះកំណើតដែលជាកេរ្តិ៍ពីឪពុកខ្ញុំ សង់នៅក្បែរផ្លូវមួយក្នុងទីជនបទ ។ គេហស្ថាននេះសង់ដោយឈើប្រក់ក្បឿង

ដែលផ្លាស់ពណ៌ក្រហមទៅជាពណ៌ដីប្រផេះ បង្ហាញឲ្យគេដឹង ថា ផ្ទះនេះសង់ជាយូរឆ្នាំណាស់មកហើយ ។

គ្រាណាខ្ញុំបានធ្វើដំណើរទៅកាន់លំនៅនេះម្ដង ៗ ខ្ញុំឈានជើងដើរចូលដោយអាក់អួលចិត្តក្រៃលែង ដ្បិតមានវត្ថុជាអនុស្សាវរីយ៍ជាច្រើនសំរាប់ដាស់ស្មារតីខ្ញុំឲ្យរលឹកឃើញដល់រូបលោកឪពុកខ្ញុំដែលបាត់បង់ជីវិតទៅជាយូរយារហើយ ។ ពីមុខផ្ទះ, របងអម្ពិលទឹកដែលខ្ញុំធ្លាប់ឃើញឪពុកខ្ញុំកាត់ផ្ទេរម ជាញឹកញាយពីគ្រាដែលលោកគង់ជីវិតនៅឡើយនោះ ឥឡូវនៅតែស្រស់ញញឹមដដែល ។ * ដើមដូង, ស្លា, ខ្នុរ, ក្រាំបែកទៀប ដុះជង្ហើគ្នាតាមរបង ដែលជាស្នាដៃរបស់ខ្មោចឪពុកខ្ញុំបណ្ដុះបណ្ដាលនោះ, កំពុងបក់ញោយស្លឹកតាមកម្លាំងវាយោ ពាក់បេះស្រដីសួរសុខ-ទុក្ខ ឬ សម្ដែងស្វាគមន៍ចំពោះរូបខ្ញុំដែលទើបនឹងមកដល់ ។ ខ្ញុំឈានជើងជាន់ឡើងលើកាំជណ្ដើរប្រកបដោយទឹកចិត្តក្រៀមស្ងួតក្រៃលែង ។

គឺជាទីនេះហើយ ដែលខ្លួនខ្ញុំធ្លាប់បានត្រេកត្រអាលយ៉ាងសែនសុខជាមួយអ្នកដ៏មានគុណឥតរង្គៀសឡើយ ។ អភ័ព្វអ៊ុហ៎ ! ក៏ពេលនេះខ្ញុំមិនបានយល់ភ័ក្ត្របុព្វការីជនរបស់ខ្ញុំដូចពីកាលម្ភៃឆ្នាំមុនទៀត ? លោកអញ្ជើញទៅណា ? ទៅចោលខ្ញុំឲ្យនៅរក្សាផ្ទះកំណើតខ្ញុំដ៏ក្រៀមក្រំ ។

លី-ធាមតេង

ក- ពន្យល់ពាក្យ

គេហស្ថាន : លំនៅ, ផ្ទះ, កន្លែងជ្រកនៅ ។

ទីជនបទ : ទីដែលនៅឆ្ងាយពីក្រុងធំ ។

វាយោ : ខ្យល់, ព្រះពាយ, វាតា ។

ស្វាគមន៍ ដំណើរល្អ,ប្រសិទ្ធិឲ្យបានដំណើរសុខ (Bienvenue)

បុព្វការីជន: បុគ្គលដែលបានទំនុកបំរុងពីមុនមក(មាតាបិតា)។

១- អក្ខរាវិរុទ្ធ

ក្បែរ (មាន រ នៅខាងចុង)

ផ្លាស់ (សរសេរ ផ ជើង ល ស្រៈអា ទីង ស សង្កត់)

ផាស់ (សរសេរ ផ ស្រៈអា ទឹង ស សង្កត់)

យូរយារ (យូ មាន រ, យា មាន រ )

ដង្ហែ ( គ្មាន រ ទេ )

ហ្ន៎ ( សរសេរ ហ ជើង ន កាកបាទពីលើ)

គ- ពាក្យស័ព្ទ

កេរ្តិ៍ ន. ( ទ្រព្យធនអាកេរ្តិ៍ពីឪពុកម្ដាយ)

កេរ ក. ( ស្រីខ្វះបួលចិត្តនិយាយកេរគេ )

ទៀប ន. ( ទៀបមួយដើមផ្លែយ៉ាងច្រើន )

ទៀប ន. (គេដាក់ទំក្នុងបានទៀប )

រៀប អានិ. ( ព្រះអាទិត្យរៀបនឹងអស្ដង្គត )

ទាប គុ. ( សង់ផ្ទះទាបក្បែរដី )

---

# ៦ - វិស្សមោកាស

ដូងជាសញ្ញាបានបន្លឺស្នូរឡើង ឲ្យសិស្សទាំងឡាយ ដឹងថាជាពេលឈប់សំរាកចំនួនដប់ប្រាំនាទីមកដល់ហើយ ។ គ្រូអនុញ្ញាតឲ្យសិស្សចេញពីក្នុងថ្នាក់ ទៅលំហែខ្លួនឯក្នុងទីធ្លា ដែលលំអដោយសួនរុក្ខជាតិ និង ដើមបុប្ផានានា ។ សំឡេងអ៊ូអរកើតមានឡើងភ្លាម ។

នុះហ្ន ! នៅក្រោមម្លប់ស្វាយ, ក្មេងតូចៗ ប្រជុំគ្នាលេងល្បែងកូនឃ្លី ស្រែកហ៊ោកញ្ជ្រៀវខ្ទររំពង ។ ឆ្ងាយពីនេះបន្តិច, សិស្សខ្លះទាត់សី លើកជើង, លើកដៃ, រត់ដេញតាមសី បញ្ចេញស្នៀតយ៉ាងស្វាហាប់ ញើសហូរស្រោកពេញទាំងខ្លួន ។ ចំណែកសិស្សធំៗ បន្តិច, មិនសូវរវល់

ដូចគេទេ  ថែរដានាំគ្នាឈរប្រជុំនិយាយចំអកចំអន់គ្នាសើចអឹងកង ។ ខ្លះមិនសូវបានរៅហារក៏ឈររហៃបចាំ ស្ដាប់សិស្សចំបងម្នាក់និទានរឿង ដែលគេធ្លាប់ប្រទះឃើញក្នុងសៀវភៅៗ សិស្សមួយហ្វូងទៀត កំពុងរត់វាញ់ដេញដណ្ដើមកូនបាល់តូចមួយដែលគេបោះចុះ, បោះឡើងពីម្នាក់ទៅម្នាក់ ។

ពេលដែលសិស្សកំពុងតែសប្បាយ សូរជួងបានបន្លឺឡើងហាក់ដាច់មេត្តា បង្ខំឲ្យសិស្សានុសិស្សចូលទៅកាន់ថ្នាក់រៀនវិញ ។

លី- ធាមតេង

ក- ពន្យល់ពាក្យ

វិស្សមោកាសៈ ឱកាសឈប់សំរាក (la récréation) ។

សួនរុក្ខជាតិៈ សួនដាំកូនឈើស្រស់ ។

យ៉ាងស្វាហាប់ៈ យ៉ាងអង់អាច, យ៉ាងខែងរែង ។

និទានរឿង : និយាយរឿង (Raconter d'une histoire) ។

រត់រៃញ : រត់ប្រសាច, រត់ចល់ ។

សិស្សានុសិស្ស : (សិស្ស + អនុសិស្ស) សិស្សជាច្រើន ។

១- អក្ខរាវិរុទ្ធ

សំពត (សរសេរឥតសង្កត់ទេ)

នុ៎ះហ្ន៎! (កុំសរសេរ នោ៎ះន!)

ហៅ (សរសេរគ្មាន រ ទេ)

ហូរ (ហូរមាន រ ឯហៅឥត រ ទេ)

គ- វាក្យស័ព្ទ

អនុញ្ញាត ន. (សិស្សសុំអនុញ្ញាតពីគ្រូឈប់បីថ្ងៃ)

អនុញ្ញាត គុ. (លិខិតអនុញ្ញាត)

អនុញ្ញាត កិ. (គ្រូអនុញ្ញាតឲ្យសិស្សឈប់បីថ្ងៃ)

ប្រោះ កិ. (ជោះបានចោលទៅដី)

ប្រោស កិ. (ជារស្រីបោសសំអាតផ្ទះ)

---

## ៣_ វិស្សមកាល

វិស្សមកាល! អ្នកផងគង់ជ្រាបស្រាប់ហើយនូវកំឡាំងនៃសេចក្ដីសប្បាយដែលតម្រឹកទ្រូងនៃយុវជនសាលារៀននៅពេលដែលជំពើបលើឈប់ពីរខែ ៗ រ៉ាកងធំ! ឈប់ពីរខែ! ពាក្យចំឡែកអស្ចារ្យដែលបើកទ្វារដើរមេឃដ៏ទូលាយទៅខាងមុខបាន ៗ បក្សីដែលគេបង្ខាំងនៅក្នុងទ្រុងហើយបើគេបើកទ្វារលែង មានសេចក្ដីត្រេកអរយ៉ាងណា-មិញ ក្មេងសិស្សទាំងឡាយ ក៏សប្បាយយ៉ាងនោះដែរ ខ្លួនគេដូចជាស្រាល ចង់សាត់អណ្ដែតទៅតាមអាកាស, កិរិយាគេដូចជាមនុស្សស្រវឹង គឺស្រវឹងនឹងសេរីភាព ឈប់

ពីរខែ! គេមិនដែលឃើញសប្បាយអ្វីបានយូរម៉េះទេ ៗ គេរួចពីចំណងនៃការរៀនសូត្រ ដែលត្រូវបំពេញរាល់ថ្ងៃជាអចិន្ត្រៃយ៍ ៗ ណាហើយសៀវភៅធំៗដ៏មានវិជ្ជាពិបាកឡើងនឹងឥតមុខ! ណាហើយសំឡេងគ្រូអាចារ្យដែលបង្ខិតបង្ខំ, ស្តីបន្ទោស, ណាហើយគ្រែដំណេកដែលមានសង្កើចពាសពេញ! ណាហើយកន្លែងទទួលភោជនាហារដែលជុំកុំនគ្នាប ៗ ជាប់នឹងប្រមុះ! ណាហើយពួកម៉ាកដែលធ្លាប់ស្រឡាញ់គ្នា, ដែលខំប្រកួតប្រណាំងគ្នា . . . ណាហើយ! ណាហើយ! គេនឹងទៅជួបជុំឪពុកម្ដាយ, បងប្អូន, ញាតិសន្ដាន ៗ គេនឹងបានដេកអស់ពេលតាមចំណង់, បរិភោគតាមឃ្លាន, ដើរលេងតាមកំសាន្ត ៗ ឈប់ពីរខែ, ជយោ!

ខ្ញ-ហាប

ក- ពន្យល់ពាក្យ

វិស្សមកាល : ពេលឈប់រៀនមានរយៈកាល (Vacances) ។

បក្សា : សត្វស្លាប, បក្សី ។

សេរីភាព : ការៈធ្វើអ្វីបានតាមបំណង (liberté) ។

អចិន្ត្រៃយ៍ : ជានិច្ចកាលពេល (ហួសនិស្ស័យ)

ភោជនាហារ : ម្ហូបចំណីជាគ្រឿងបរិភោគ ។

១- អក្ខរាវិរុទ្ធ

វិស្សមកាល (សរសេរ ស ជើង ស)

ត្រេកអរ (មាន រ នៅខាងចុង)

អចិន្ត្រៃយ៍ (សរសេរ យ បដិសេធ)

ក្អួន (សរសេរ ក មិនមែន ខ ទេ)

គ. វាក្យស័ព្ទ

ពីរ គុ. (ខ្ញុំមានកូនពីរនាក់)

ពី កិ. (អ្នកមកពីណាមក)

នៅ កិ. (ផ្ទះខ្ញុំនៅក្នុងក្រុងភ្នំពេញ)

ជូន និ. (ខ្ញុំជូនលោកនូវសព្ទសាធុការ)

---

## ៨_កុំទុំមុនស្រគាល

ផ្លែឈើទាំងពួង ដំបូងលេចចេញមកជាក្តិប, រួចពីក្តិបទៅជាខ្ចី, រួចពីខ្ចីទៅជាចាស់ លុះរួចពីចាស់ទើបទៅជាស្រគាល ផុតពីស្រគាលទើបទៅជាទុំ តាមលំដាប់គ្នាហូរហែ មិនដែលផ្លែឈើណាទុំរួចបានចាស់ រួចបានខ្ចីវិញនោះទេ ។

សុភាសិតនេះ ជាពាក្យប្រៀបធៀប ។ បុរាណាចារ្យយើងលោកប្រដៅមនុស្សថា កុំឲ្យធ្វើជាចេះដឹងមុនការរៀនសូត្រ ។

កុំឲ្យតាំងខ្លួនធ្វើជាអ្នកមានស្តុកស្តម្ភមានទ្រព្យសម្បត្តិ ។
កុំឲ្យតាំងខ្លួនធ្វើជានាម៉ឺនមុននឹងមានព្រះរាជប្រកាសតាំង ។
បើលើកខ្លួនខុសទំនងដូចពោលមកខាងលើនេះ មុខជានឹងវិនាសដោយហេតុណាមួយមិនខានឡើយ ។

មានន័យមួយទៀតលោកប្រៀបថា កំឡោះក្តី, ក្រមុំក្តី, ដែលជនជាអាណាព្យាបាល -មានមាតាបិតាជាដើម, មិនទាន់រៀបចំទុកដាក់ខ្លួនត្រឹមត្រូវឲ្យមានអាពាហ៍ពិពាហ៍ទេ ហើយស្រាប់តែប្រព្រឹត្តរំលោភគន្លងប្រវេណីនោះ ក៏លោកចាត់ទុកថា "ទុំមុនស្រគាល" ដែរ ។

ប៊ូ – ប៉ូ

ក- ពន្យល់ពាក្យ

សុភាសិត : ពាក្យទំនៀមដ៏ល្អប្រសើរ ។

បុរាណាចារ្យ : បុគ្គលជាគ្រូជាន់ដើម, ជាន់មុន ។

ព្រះរាជប្រកាស : សេចក្តីផ្សាយចេញពីព្រះរាជា ។

អាណាព្យាបាល : អ្នកទំនុកបំរុង, អ្នកថែរក្សា
ប្រវេណី : ច្បាប់ដាច់ទម្លាប់, ទំនៀមទម្លាប់ ។

ខ- អក្ខរាវិរុទ្ធ

ស្រគាល (សរសេរ គ ស្រៈ អា)

សុកសម្ភ (សរសេរ ម ជើង ភ)

បិតា (អ.ថ. បីដា សរសេរ បិតា)

គ- វិភាគស័ព្ទ

ទុំ គុ. (ផ្លែឈើទុំមានរសជាតិផ្អែម)

ទំ កិ. (ចក្សុទំលើមែករុក្ខា)

ការ ន. (ការរៀនសូត្រ, គេធ្វើការ)

ការ កិ. (បងទូកការខ្យល់ព្យុះ)

ការ កិ (ស្រីការសូត្រដាក់បំពង់)

កាណិ ន (ព្រះរាជបុត្រីទ្រង់កណ្ដាល់នៅព្រះកាណ៌)

ការណ៍ ន. (ហេតុ, ដំណើររឺងការណ៍សុទ្ធជារឿងរ៉ាវ)

កា កិ. (ខ្ញុំកាន់សំបុត្រផ្ញើទៅប្អូនខ្ញុំ)

កា ន (ខ្ញុំផឹកទឹកអស់មួយកា)

ប្រកាស ន. (ប្រកាសមួយហាមមិនឲ្យលក់ស្រាថ្ងៃសីល)

ប្រកាស កិ. (រាជការប្រកាសឲ្យរាស្ត្រមកបង់ពន្ធ)

នឹង និ. (ខ្ញុំនឹងបងខ្ញុំប្ដូលហ៊ុនគ្នារកស៊ី)

ហ្នឹង វិ.ស. (រឿងហ្នឹងជារឿងបំភ្លេក)

នឹង គុ ឬ.កិ.វិ. (ទ្វារធំបើកទៅនឹងថ្កល់)

នឹង កិ.គុ. (ស្អែកខ្ញុំនឹងទៅលេងជាមួយអ្នក)

ណា សព្វ. (កាលណាបានអ្នកមកជួបខ្ញុំ)

ហ្នា ឬ ណា និ. (កុំខឹងហ្នាណាងក្មេង)

## ៩ - ទីក្រុងសៀមរាប

បណ្ដាក្រុងទាំងឡាយ ដែលជាទីរួមខេត្តក្នុងកម្ពុជរដ្ឋ បើនិយាយតាមទីកន្លែងជារមណីយដ្ឋាន ក៏មិនមានក្រុងខេត្តណាយកឈ្នះក្រុងសៀមរាបបាន ពិតមែនតែក្រុងនេះតូចជាងគេ ។

តាមដងស្ទឹង, មានផ្លូវនៅត្រើយទាំងសងខាង ប្រកបដោយព្រឹក្សាជាដំណាំ មានស្លឹកខៀវខ្ចី ត្រជាក់ត្រឈឹងត្រឈៃគួរជាទីកំសាន្ត ។ ទឹកស្ទឹងថ្លាហូរពេញត្រៀបមាត់ច្រាំងហូររមៗ, មានរហាត់ទឹកវិលរគាំងឮសូរផ្ដើតអែប... តាំងពីខាងលើផ្សាររហូតទៅខាងក្រោមផ្សារគួរឲ្យគយគន់ ។

នៅតាមមាត់ស្ទឹងត្រើយទាំងសងខាង មានវត្តជាច្រើន តែវត្តដែលគួរចូលមើលនោះគឺវត្តព្រហ្មរ័ត្ន ដែលជាវត្តបុរាណជាងគេប្រកបក្បាច់នគរជាន់ថ្លៃបំណាន ។

a côté

នៅក្បែរស្ពានថ្ម មានទីកន្លែងសម្រាប់ចិញ្ចឹមសត្វ ។ ត្រង់នេះមានមហាសណ្ឋាគារមួយយ៉ាងទាន់សម័យ សំរាប់ទទួលពួកទេសចរ ។

ជ៉ាង-ខាត់

## ក- ពន្យល់ពាក្យ

ទីរួមខេត្រ : ទីប្រជុំជនរបស់ខេត្រ (Chef - lieu) ។

រមណីយដ្ឋាន : ទីដែលជាសុខមនោរម្យ ។

ព្រឹក្សា : ដើមឈើ, ព្រៃដែលឈើដុះច្រើន ។

មហាសណ្ឋាគារ : ផ្ទះសំណាក់យ៉ាងធំ (grand hotel)

ទេសចរ : អ្នកដើរទស្សនា, អ្នកធ្វើដំណើរ (touriste)

## ខ-អក្ខរាវិរុទ្ធ

ខេត្រ ឬ ខេត្ត (សរសេរបានទាំងពីរបែប)

កម្ពុជរដ្ឋ (កុំសរសេរកម្ពុជៈរដ្ឋ)

សណ្ឋាន (កុំសរសេរ សន្ឋាន)

ហ្វង់ (អ.ថ. វ៉ង់ តែសរសេរ ហ្វ)

សំរាប់, សម្រាប់ (ដាក់បានទាំងពីរបែប)

គ– ពាក្យស័ព្ទ

ត្រៀប គុ. (ទឹកឡើងពេញត្រៀបមាត់ប្រាំង)

ប្រៀប កិ. (កញ្ញានេះល្អ ប្រៀបដូចជាទេពធីតា)

ព្រាប ន. (សត្វព្រាបយំថ្ងូរលើដំបូលវិហារ)

សម័យ ន. (វត្តទំនើប ជាវត្តសម័យថ្មី)

ស្រមៃ កិ. (ខ្ញុំស្រមៃឃើញខ្មោចឪពុកខ្ញុំ)

សូមៃ ន. (នាងតបសូមៃទៅស្វាមីវិញភ្លាម)

ទេសចរ ន.ឬ គុ. (ពួកទេសចរដើរលេងអង្គរ)

ទេសចរណ៍ ន. (ទេសចរណ៍ជាការទាក់ទងរវាងប្រទេស)

ជាន់ កិ ឬ ន. (អង្គរវត្តជាប្រាសាទជាន់ចាស់)

ជន់ កិ. (ទឹកទន្លេជន់លិចភូមិ)

ជន ឧ. ( ជនគីមួយ ៗ ត្រូវបេះអក្សរ )

ជន្ម ឧ. ( ព្រះជិនវង្សបានប្រហារជន្មយក្ស )

---

# ១០– ទេសភាពមាត់បឹង

ទិដ្ឋភាពផ្ទៃបឹង ត្រជាក់ចំពោះអ្នក ណា ដែលបានទៅកំ-ស្សាន្ត នូវសម្រស់ដ៏ល្អ ធើតគួរជាប់ចិត្ត ។

គេឃើញមានគុម្ពោតត្រស់នឹងពំង លេចត្រយួរហាន់មានតាបមានខ្ពស់ គួរជាទីអាស្រ័យនៃបក្សាបក្សីទាំងឡាយ ។ សព្វសត្វដែលត្រូវត្រាច់រកម្ហូបជាចំណី ហិចហើរប្រៀវប្រែប្រវ៉ាត់ទៅមក ។ ខ្លះហក់មុជបុះក្ដុំទឹកដូចជាមិនបេះល្អក់សោះ ។ សេចក្ដីពង់រៀបនៃសារិកាកែវ ទន់ត្រលន់-ត្រលោនមិនបេះឈប់ឈរ ហាក់ដូចនិមានរឿងគួមួយយ៉ាងវែង ហើយពិរោះប្លែក ។ ដើមព្រលិត, កញ្ឆែត,

កំពីងពួយ ទឹងត្រកួន អើតតរហោងពីក្នុងផ្ទៃបឹង ៗ ខ្លះលោតផ្កាប្រឡូយបញ្ចេញពណ៌ផ្សេង ៗ រង់ចាំស្តាប់រឿងដំពិរពេះនៃសត្វទាំងនោះ ៗ ព្រៃយោបក់បោយ បណ្ដាលឲ្យក្រមើកអស់ស្លឹករុក្ខជាតិ ទឹងព្រៃជាតិទាំងចាស់-ខ្ចី ឲ្យយោលរេច ៗ ប្រៀបដូចជាចាក់ត្នុកជាក់គ្នាពុំចេះនឿយហត់ ៗ រលកតូច ៗ រមៀលអន្ទាញ់ដេញប្រលែងគ្នាតួនចុះតួនឡើង បញ្ចេញអ្នកប្រកិរិយាឲ្យដឹងថាសប្បាយក្រៃលែង ៗ ដូនជាអាកាសស្អាតផ្ទេង មានដុំពពកមួយ ៗ រសាត់កៀនលយផង នាំឲ្យធ្លុះឃើញស្រមោលនៅក្នុងទឹកថ្លាឈ្វេង បដូចជាមានមេឃមួយទៀតយ៉ាងថ្មែក នៅក្នុងបឹងនោះឯង ៗ

នេះហើយជាទេសភាពដែលនាំឲ្យយើងចាប់អារម្មណ៍ក្រៃលែង ៗ

លី - ណាមគេង

ក- ពន្យល់ពាក្យ

ទេសភាព : សភាពប្លែករបស់ស្រុក (Paysage) ។

ទិដ្ឋភាព : ភាពអ្វីដែលគេដាក់ឲ្យឃើញ (Aspect) ។

មច្ឆា : ត្រី, ហ្វូងសត្វត្រី ។

និទានរឿង : និយាយរឿង, ថ្លែងរឿង ។

វារីជាតិ : ពួកដើមឈើតូចៗដុះកណ្ដាលទឹក ។

អកម្មកិរិយា : ពុកពាក្យកេតសម្គាល់បាន ។

ចាប់អារម្មណ៍ : ទាក់ចិត្ត, ដក់ជាប់ក្នុងចិត្ត (Impressionner) ។

១ - អក្ខរាវិរុទ្ធ

គុម្ពោត ( សរសេរ គ ស្រៈ អុ )

គ្រាប់ ( សរសេរគ្រាប់ ប្ដូរគ្រេប )

មុជ ( សរសេរប្រកបទីង ជ )

ត្នុក ( សរសេរ ត ជើង ល )

មេឃ ( សរសេរ មេ ទីង ឃ )

គ - វាក្យស័ព្ទ

ត្លុក ន. (អ្នកកំប្លែងលោតពាក់ត្លុក)

ថ្លុក ន. (ទឹកភ្លៀងហូរធ្លាក់ក្នុងថ្លុក)

ផ្អៀង កិ.ឬ គុ. (ទ្រង់ផ្អៀងយល់, ទឹកថ្លាផ្អៀង)

ឆ្វេង គុ. (ក្មេងដំបៅកែងដៃឆ្វេង)

---

## ១១ ក្អែកមួយជាក្អែកដប់

មានសេចក្តីនិទានថា កាលនោះ បុរសម្នាក់ដើរទៅក្នុងព្រៃ ប្រទះនឹងមាសប្រាក់ជាច្រើន រកមើលម្ចាស់ពុំឃើញ ៗ បុរសនោះពុំហ៊ានយកឡើយ ព្រោះខ្លាចបែកការណ៍នឹងមានទោសដល់ខ្លួន ទើបគិតថាចាំអញពិសោធមើលចិត្តប្រពន្ធអញសិន ៗ លុះមកដល់ផ្ទះ បុរសនោះប្រាប់ប្រពន្ធថា "អញចូលទៅបត់ជើងក្នុងព្រៃ ស្រាប់តែសត្វក្អែកមួយ

ហើរចេញពីទ្វារធំអញទៅ ឯងណាក់ឲ្យជិតខ្ជាប់ក្រែងបែកការណ៍កើតនិន្ទាដល់របអញ" ។

ឯប្រពន្ធណាក់រឿងនេះមិនបាន ក៏និយាយប្រាប់ស្ត្រីម្នាក់ខ្លួនថា "មានក្អែកពីរចេញពីទ្វារលាមកប្តីទៅ" ។ ស្ត្រីនោះឯង និយាយប្រាប់គ្នាតៗ ទៅរហូតដល់ក្អែកឡើងដល់ដប់ ។ រឿងនេះជ្រាបដល់ស្តេច, ព្រះអង្គហៅបុរសប្តីទៅសួរ ទ្រង់ជ្រាបថាមិនពិតទេ គឺគ្រាន់តែពាសោធចិត្តប្រពន្ធប៉ុណ្ណោះ តាមពិត ដើមហេតុគឺមាសប្រាក់នៅក្នុងព្រៃ ។ ព្រះអង្គទ្រង់ប្រើឲ្យទៅយកមាសប្រាក់នោះមកចែកបុរសនេះពាក់កណ្តាល យកដាក់ឃ្លាំងព្រះរាជទ្រព្យពាក់កណ្តាល ។

ប៊ូ - ក៊ូ

ក- ពន្យល់ពាក្យ

និន្ទា : ពាក្យរិះគន់, តេរ, ហេតុគួរខ្មាស ។

លាមក : កាកអាហារចាស់, អាចម៍ ។

ម្រាក់ : មិត្តជាស្រីដូចគ្នា ។

ព្រះរាជទ្រព្យ : ទ្រព្យសម្បត្តិសំរាប់ព្រះរាជា ។

១- អក្ខរាវិរុទ្ធ

លាមក (អ ថ លាមក់ ឥតមានបន្តក់ទេ)

មាស (ឥតមានបន្តក់ទេ)

គ- ពាក្យសព្ទ

ពិសោធ កិ. (ប្ដីពិសោធចិត្តប្រពន្ធ)

ពិសោធន៍ ន. (គេធ្វើពិសោធន៍មើលជាតិឧសថ)

ឈាក់ កិ. (ឈាក់សម្លួយបាន, ជាតិឈាក់ឈើ)

លក្ខណ៍ ន. (ស្រីល្អគ្រប់លក្ខណ៍កម្រកបាន)

ល័ក្ត ឬ ល័ខ ន. (ស្បង់លោកជ្រលក់ល័ក្តលឿង)

លក្សណ៍ ន. (ព្រះលក្សណ៍លើកទ័ពទៅច្បាំង)

ទ្រព្យ ន. (សម្បត្តិទាំងនេះជាទ្រព្យរបស់ខ្ញុំ)

ទ្រាប់ ក. (ក្រាលកន្ទេលទ្រាប់ក្រោមគូថ)

គ្រប់ ខ. (សម្លកក្បូរផ្លែគ្រប់)

---

## ១២ – ស្រះស្រង់

ស្រះស្រង់មានសណ្ឋានបួនជ្រុងទ្រវែង ប្រកបដោយកំរាលថ្មជាជណ្ដើរចុះទៅកាន់ទឹក ។ នៅមាត់ស្រះ មានដើមឈើដុះព័ទ្ធជុំវិញ មានម្លប់ត្រជាក់ត្រឈៃ បណ្ដោយប្រាំបីរយម៉ែត្រ ទទឹងប្រហែលបួនរយម៉ែត្រ ។

ទិសខាងលិចជាមាត់កំពង់ គេកសាងជាទីលានខ្ពស់ ប្រកបដោយបង្កាន់ដៃនាគស៊ើនប្រឹងប្រាងចុះទៅកាន់ទឹក ។ ពេលព្រះសូរិយាលិចចុះកាន់អស្ដង្គតប្រទេស , បញ្ចេញពន្លឺរន្ទាលប៉ះមកលើទីលាននេះ បើជាយើងឈប់សម្រាកបន្តិចឈរមើលទៅខាងកើតនៅពេលនុះ រឹតតែល្អមើលណាស់ ៗ

នៅកណ្ដាលស្រះមានប្រាសាទតូចមួយ តែឥឡូវនេះវិនាសហើយ មើលទៅឃើញតែដុំថ្មខ្មៅៗ ។ នៅខាងត្បូងជាទីលាន មានសាលាប្រក់ក្បឿងមួយ ជាទីសំចត ឬសម្រាប់បរិភោគអាហារ ។

ប៉ាង - ខាត់

ក- ពន្យល់ពាក្យ

សណ្ឋាន: ទ្រង់ទ្រាយ, ពងរេ, សភាព ។

នាគស្ងើន: នាគងើបក្បាល, នាគអើតក្បាល ។

គស្ដុគប្រទេស: ទីឬ តំបន់ដែលថ្ងៃលិច ។

ទីលាន: ទីវាល, វាលសំពប់កសាន្ដឬហ៊ុកហាត់អ្វីមួយៗ

១- អក្ខរាវិរុទ្ធ

សណ្ឋាន (ដើង ឋ មិនមែនដើង ថ ទេ)

ព័ន្ធ (ប្រយ័ត្នកុំសរសេរ ពាត់ ឬ ព័ត្ឋ)

ប៉ះ (សរសេរ ប៉ វិសជ្ជនីយ)

ប្រក់ (សរសេរមានរស្រៀសញា)

សម្រាប់ ឬ សំពប់ (ដាក់បានទាំងពីរបែប)

បរិភោគ (សរសេរប្រកបនឹងអក្សរ គ)

គ- ពាក្យស័ព្ទ

ទុះ សព្ទ. (ទុះឯងជាប្រាសាទស្រះស្រង់)

នោះ វិ.ស. (រូបសីហៈទាំងនោះ ងើយមុខស្មើន)

លាន ន. (ពួកបរិវារប្រជុំគ្នានៅក្នុងលាន)

លាន ប.ស. (ឆ្នោតពិសេសរង្វាន់ធំត្រូវបានបីលានរៀល)

---

## ១៣- អ្នកតាដំបងដែក

នៅក្បែរដងផ្លូវ ដែលនៅជាយព្រៃមួយ, មានដើមពោធិធំមួយដើមបែកមែកសាខា ហើយបោលមួបត្រឈើនគ្រៃឈ នៅលើដីទំពែកដែលឥតស្មៅដុះ ។ កាលបើមានខ្យល់បកមកម្ដង ៗ ស្លឹកព្រឹក្សនោះបញ្ចេញសូរព្រោះ ។

បីដូចជាគេញាក់ញីក្រដាស ៗ ឯចុសដែលសំយុងចុះពីមែក ក៏យោលទោដូចជាខ្សែដងក្តោងនាវាមួយដែរ ៗ

នៅជាប់ទីងគល់ដែលមានផ្ចត់ក្ញួញ ៗ នៃស្តេចឈើនេះ មានកូនខ្ទមមួយនៅជ្រកកំប្រោន. ដ៏មានដំបូលធ្វើពីបន្ទះក្តារ ពុករលើករយោក គ្រាំគ្រាដោយជរាភាព ៗ កំទេចឆ្អឹងមាន់, ទា, ឆ្អឹងជូប, ស្លឹកចេក ដែលមានគ្រាប់ផ្កាយក្រៀមក្រពិត នៅជាប់, ក៏មាននៅដេរដាសលើក្តារក្រាលនៃកូនខ្ទម ៗ

ខាងក្នុងកូនរាននេះ ដែលមានងងឹតស្អាប់ ៗ តាំងនៅ, មានបដិមាមួយឆ្លាក់ខ្ជីខ្ជាពីថ្មពណ៌ប្រផេះ មាឌប៉ុនកូនក្មេង អាយុប្រាំឆ្នាំ ពានាកនៃស្រង់ពណ៌លោហិត ដៃកាន់ដំបងមួយ យ៉ាងធំ ហើយធ្វើមុខក្រញីវក្រញូវ មាត់ពេបស្បៀបទៅ រកវាលស្រែ ដែលនៅចំពីមុខខ្លួន ៗ រូបនេះហើយ ជាតួ

អ្នកតាដំបន់ដែក ដែលមានបុទ្ធិចេស្ដា ធ្វើឲ្យអ្នកភូមិជិតខាងខ្លាចញាប់ញ័រគ្រប់ៗគ្នា ។

ខ - ឃ្លាច

ក— ពន្យល់ពាក្យ

ដីទំពែក : ដីវាលគ្មានស្មៅដុះ ។

ស្តេចឈើ : ឈើយ៉ាងធំ, ដើមឈើធំលើសលែង ។

ជរាភាព : សភាពចាស់ទ្រុឌទ្រោម ។

ងងឹតស្អាប់តាំងនៅ : នៅកន្លែងងឹតឥតយល់ពន្លឺច្បាស់ៗ

ពានាគនៃឡង់ : បង់គកនៃឡង់ពាក់ឈៀងទៅម្ខាង ។

បុទ្ធិចេស្ដា : បុទ្ធិអំណាច, បុណ្យបារមី ។

១- អក្ខរាវិរុទ្ធ

អួរ ( មានរ នៅចុង )

ដុះ ( សរសេរ ដ ស្រះ អុ វិសជ្ជនីយ )

ក្រដាស (ឥតមានសេស្រសញ្ញាពីលើទេ)

ក្ការ (សរសេរមាន រ នៅចុង)

ញ៉ែរ (សំយោគសញ្ញាត្រូវដាក់លើ ញ)

គ- ពាក្យស័ព្ទ

ដុះ កិ. (ដើមឈើដុះនៅក្នុងព្រៃជាច្រើន)

ដុស កិ. (ដាងដុសខាត់តុទូឡូរលោង)

ព្រឹក្សា ន. (បក្សីទំលើមែកព្រឹក្សា)

ប្រឹក្សា កិ. (ពូសុខពូសៅប្រឹក្សាការជាមួយគ្នា)

ពានា កិ, (ខបាសិកាពានាសំពត់ស)

ពណ៌នា កិ. (ខ្ញុំសូមពណ៌នាពីរឿងទេវ័ន្ត)

---

## ១៤- ភូមិទួលកី

តាមដងផ្លូវទៅកំពត ចំងាយដប់ប្រាំគីឡូម៉ែត្រពីភ្នំពេញ មានភូមិមួយដ៏មានផ្ទះដាច់ៗ ពីគ្នា ខ្ទះសង់ក្រោមដើមត្នោត

ខ្ទះក្រោមបុស្ស៊ី ខ្ទះព័ទ្ធជុំវិញដោយដើមបេក ។ ភូមិនេះឯងមាននាមប្រាកដសព្វថ្ងៃនេះ ថាភូមិ "ទួលកី" ប៉ុន្តែក្នុងបុរាណកាល ភូមិទួលកីបានសន្មតហៅថាភូមិ "ទល់កេរ្ដិ៍" ទេ ។ ព្រោះរឿងព្រេងប្រចាំស្រុកបានដំណាលថា នៅកន្លែងនោះ ព្រះមហាក្សត្រសម័យបុរាណវៃឆ្ងាយមួយព្រះអង្គទ្រង់បានបែកកេរ្ដិ៍ដល់សេនាឯកព្រះអង្គមួយ រូបដល់ត្រឹមនោះ ។

សង្ខាងផ្លូវរទេះមួយ គេឃើញដុះដើមសង្កែ ដើមរពាក់ ដើមត្នោតក៏មានដែរ ។ ផ្លូវរទេះនេះឯង មើលទៅ ដូចជាល្បូនដំរង់ទៅផ្ទះពីរ-បីនៅឯនាយ ប៉ុន្តែមិនយ៉ាងនេះទេ វាទៅជាក្រវេចក្រវៀនហួសពីនោះទៅទៀត រួចបែកជាពីរ មួយទៅឯព្រៃត្នោតឯនាយឆ្ងាយនោះដែលលេចនៅជាចន្លោះដំបូលស្លឹកបីបួននៃផ្ទះអ្នកស្រុក, មួយទៅកំបាំងបាត់នឹងព្រៃរពាក់លាយឡំនឹងរុក្ខាឯទៀតច្រើន ។

វិម-គិន

## ក- ពន្យល់ពាក្យ

រឿងព្រេង : រឿងនិទានតៗគ្នាមកជាអង្វែងហើយ ។

បុរាណកាល : ពេល, វេលាពីយូរមកហើយ ។

សេនាឯក : សេនាចំបង, សេនាជំនិត, នាម៉ឺនធំ ។

## ខ- អក្ខរាវិរុទ្ធ

បំភាយ ឬ បម្ភាយ (ដាក់បានទាំងពីរយ៉ាង)

ខ្នាត (សរសេរ ត ជើង ន មិនមែន ថ ទេ)

សន្តុត (ឥតមានស្យេសញ្ញាទេ)

លាយឡំ (កុំសរសេរ លាយលំ)

រុក្ខា (កុំសរសេរ រុក្ខា)

## គ- វាក្យស័ព្ទ

ឫស្សី (គេកាប់ឫស្សីយកមកធ្វើរនាបផ្ទះ)

ឫសី ន. (ឫសីមួយអង្គបំរើនធម៌ក្នុងព្រៃភ្នំ)

ព្រេង ន. (សេចក្ដីដំណាលមានមកពីព្រេង)

ប្រេង ន. (ចង្កៀងតូចនេះដាក់ប្រេងបានច្រើន)

---

## ១៥ – ព្រះក្សត្រីផ្ទំស្កល់

ខ្ញុំបានស្គាល់ព្រះក្សត្រីមួយអង្គដែលផ្ទំជាទិច្ចកាល់ ៗ ឆ្នាំ ក្រោយដែលគម្ហត្តរផ្លូវកន្ទ្វងហួសទៅ ។

ព្រះនាងមិនមែនផ្ទំហូតដល់រាប់រយឆ្នាំនោះទេ, គឺគង់រវាងប៉ុន្មានខែប៉ុណ្ណោះ តែយើងនាំគ្នាជឿថា ហាក់ដូចជាមួយសតវត្ស ៗ នៅគ្រាដែលព្រះនាងផ្ទំស្កប់ស្កល់ គេមិនសូវឮសូរសម្រែកបក្សាបក្សីស្រែកខ្ញៀវខ្ញារទេ ឯស្លឹកឈើ, ផ្កាឈើក៏មិនមានលូតលាស់ឡើយ ៗ គេឃើញតែមែកគោកសម្បុរជាំស្វាំងនៅក្រោមផ្ទៃមេឃប្រផេះប៉ុណ្ណោះ ៗ ដូនកាលមានអព្ភូតគ្រប់ងងឹតផ្ទៃពសុធា, ដែលចណ្ដាលឲ្យធម្មជាតិស្ងប់ស្ងាត់ត្រឈិងប៉ដូចជាទីរហោស្ថានផង ៗ

មិនយូរប៉ុន្មាន មានក្សត្រាមួយអង្គប្រដាប់ព្រះកាយដោយពណ៌ខៀវបព្រិច បានយាងមកដាស់ព្រះនាងឲ្យតើនឡើង ដោយទ្រង់ចាប់ទាញព្រះហស្ថាដ៏ទន់ភ្លន់នៃព្រះនាងដែលកំពុងតែផ្ទំស្កប់ស្កល់ ។ គ្រានោះឯង ព្រះអាទិត្យក៏បាំងបែនរស្មី, មហាមេឃឡើងពណ៌ខៀវស្រងាត់ ត្រួយរុក្ខជាតិក៏លូតលាស់ខ្ចីល្អក់, បុប្ផាផងរីកស្គុះស្គាយ បំណែកបក្សាបក្សីក៏ស្រែកកញ្ជ្រៀវគឹកកងរំពងឆ្លើយឆ្លងគ្នា ។

ព្រះក្សត្រីនេះឯងគឺហិមន្តរដូវ ដែលមានព្រះក្សត្រាជាវសន្តរដូវមកទទួលភារៈបន្តពីព្រះនាងទៅទៀត ។

លី-ធាមតេង

## ក-ពន្យល់ពាក្យ

ហិមន្តរដូវ : រដូវរំហើយ, រដូវរងា, រដូវត្រជាក់ ។

រហោស្ថាន : ទីស្ងាត់ដែលគ្មានមនុស្សនៅ (Désert) ។

គើន : ក្រោក, ក្វាក់, ងើប (ពាក្យសព្ទ) ៗ

ព្រះហស្ថ : ដៃ (ពាក្យសព្ទ) ៗ

១- អក្ខរាវិរុទ្ធ

គម្ពុទវដ្ដុ (សរសេរខុសដើម )

ផ្ដុំ ( កុំសរសេរ ផ្ទុំ )

សម្បុរ (សរសេរដូច្នេះតែអានថាសំបុល)

ជូនប្អូន (ដាក់បានទាំងពីរយ៉ាង)

ពស្ដា (កុំសរសេរ កស្ដា)

ត្រួយ (កុំសរសេរ ទ្រួយ)

គ- ពាក្យសព្ទ

ដាស់ កិ. (ម្ដាយដាស់កូនឲ្យក្រោកឡើង)

ដាស កិ.វិ (ស្មៅដុះដាសពេញដី)

ដាស កិ.( គេដាសស្គរឲ្យតឹងល្អ )

# ១៦- វិធីបញ្ជាក់អារក្ស

នៅពីមុខកន្ទាដែលសន់ជាច្រើនថ្នាក់ ហើយដែលរៀបតុបតែងដោយស្លាធមិ បាយសី ទឹងមានធ្មែគ្រប់គ្រងពីលើ, ភ្លើងមួយវង់ប្រគុំរង្វើល ៗ តាមថ្នាក់សួរស្គរស្មើ ៗ គ្នា ៗ សំឡេងថ្មុំអព្ទគ្រលួចបណ្ដើរទំនុករបស់អ្នកច្រៀង យ៉ាងលន្ទង់លន្ទាចដែលគេហៅថាបទអន្ទង់ខ្មោច ៗ

យាយចាស់ម្នាក់ពានាសំពត់ជាតិអន្លុយញាក់ជើងម្ដង ៗ ជូនស្ងាប, ជូនបើកភ្នែកធំ ៗ រួចស្រាប់តែគ្រញែងខ្លួនពីរ-បីដង ក៏លើកដៃឡើងរាំតាមថ្នាក់ភ្លេង ៗ គាត់ក្រោកឡើងរាំរែកចាក់ក្បាច់បំទើតបំទយប្រទក្សិណកន្ទា ដែលក្មេងក្រោនក្រាតដោយពន្លឺភ្លើងទៀនទឹងធូបជំមានផ្សែងហុយខ្មោលោម ៗ គាត់រាំចាក់ក្បាច់កាន់តែញាប់ឡើង ៗ, ឯពួកភ្លេងក៏ខំសំពង់សួរឥតប្រណីដៃ ដើម្បីបំពេញចិត្តមេកន្ទោងខ្មៅ ៗ រាំអស់ចិត្ត គាត់អង្គុយចាប់គោកគ្រវី រួចសួរកេអ្នកដែលបញ្ជាន់អញ្ចើញ

អស់លោកតើមានការអ្វី? ស្ត្រីនោះក៏អណ្ដែតយកដើមខែម និយាយអង្វរករសុំឲ្យជួយសង្គ្រោះដល់ពស់ថាប ឲ្យមានព្រលឹង សម្បុរ ជាសះស្បើយឡើងវិញ ។

រូបសព្វគ្រប់ហើយ រូបមេមត់លើកដៃសំពះ រូបនេះ កន្ទុលដាំង ស្រាប់តែខ្មោចចេញបាត់ទៅ នៅសល់តែរូប ដូនចាស់ដូចធម្មតា ។

លី-ធាមតេង

ក-ពន្យល់ពាក្យ

ពនមា : ពនដែលសង់ដម្កល់គ្រឿងសក្ការៈ ។

អន្ទង់ខ្មោច : លន្ធិលោមខ្មោច, ណែនាំខ្មោច ។

ជាតី : ក្រណាត់ក្រហមជ្រលក់ស្រាប់, ក្រណាត់ពណ៌ឈាម ។

សំពន់ស្គរតេឥប្រណីដៃ : វាយស្គរយ៉ាងញាប់ដៃ ។

កន្ទ្រានទៀវ : ឈ្មោះខ្មោចអារក្សមួយយ៉ាងសាហាវ ។

គោក : ដើមពានរបស់អារក្ស ។

អស់លោក : ពាក្យសំពប់ហៅបញ្ចើបខ្មោចអារក្ស ៗ

ស្នំ : ស្ត្រីអ្នកបំរើរូបអារក្ស ៗ

ពនិចាប : ពាក្យអារក្សហៅអ្នកជម្ងឺ ៗ

១- អក្ខរាវិរុទ្ធ

ពន (កុំប្រឡំនឹង រៀន)

ស្គរ (សរសេរមាន រ នៅចុង)

ប៊ុស (ឥតមាន រ នៅចុងទេ)

គ្រលួច (សរសេរ គ្រ)

គ្រញែង (សរសេរ គ្រ)

សម្បុរ (មាន រ នៅខាងចុង)

៣– ពាក្យស័ព្ទ

វង់ ន. (ភ្លេងមួយវង់កំពុងប្រគំ)

វង់ ន. (កញ្ច្រូងមានវង់មូលក្រឡង់)

វង្ស ន. (ឯងជាវង្សត្រកូលអ្នកណា )

# ១៧- ស្ទូចត្រីនៅមាត់ស្ទឹងសែន

គូកន្ទពីរនាក់ គឺមទឹសាន រៀននៅសាលាជាមួយគ្នា ចៀតឱកាសថ្ងៃព្រហស្បតិ៍ ក៏ដើរទៅស្ទូចត្រីនៅមាត់ស្ទឹងសែន ។ លុះព្រឹកឡើងវាំនាំគ្នាចេញទៅពីព្រលឹម ដ៏មានសំលៀកបំពាក់ចាស់ៗ មួកធំសម្រាប់ដើម្បីបាំងចំហាយព្រះអាទិត្យផង ។ ចៅគឹមលីដងសន្ទូចមួយ ដ៏មានខ្សែ, ផ្លែសន្ទូច, កំស្ទួលនិងប្រអប់ជាកន្ទុយ ។ ចៅសានកាន់ល្អីស្បៀងអាហារ ។ ក្មេងទាំងពីរទៅឈប់នៅកន្លែងមួយនាមាត់ទឹកដ៏មានម្លប់ល្អ ។ វាស្ទូចនៅទីនុះ ។ ដំបូងគ្មានត្រីមកស៊ីសោះ គឹមនិងសានពុំហ៊ានកំរើកខ្លួនឡើយក្រែងត្រីភ្ញើល ។ មួយស្របក់ មានត្រីច្រើនហែបហែលនាផ្ទៃទឹក ។ កំស្ទួលសន្ទូចកម្រោលឡើងម្ដងៗ គឺត្រីស៊ីសន្ទូច ។ វាវាត់ដងសន្ទូចឡើងបានត្រីមួយៗ មិនយូរប៉ុន្មានវាបានត្រីពេញត្រក

## គ. ពាក្យស័ព្ទ

គូ ន.( គូស្វាមីភរិយា, ផ្កាមួយគូ )

គូរ កិ.( ជាងគូររូបទេសភាពយ៉ាងល្អ )

នាក់ ន.( មនុស្សបីនាក់មកដល់ផ្ទះខ្ញុំ )

អ្នក ន.( អ្នកណាខ្លះចង់ទៅផ្សារ )

វ៉ាត់ កិ.( ពៅសានវ៉ាត់សន្ទូចឲ្យឆាប់ត្រី )

វត្ត ន.( ព្រះសង្ឃគង់នៅក្នុងវត្ត )

វត្ត ន.( កូនត្រូវធ្វើវត្តប្រណិបត្តន៍ឪពុក-ម្ដាយ )

វត្ស ឬ វត្សរ៍ ន.( មួយសតវត្សមាន១០ឆ្នាំ )

វ័ធ កិ.( ក្របីវ័ធកូនក្មេងទាល់តែធ្លាយពោះ )

វឌ្ឍន៍ ន.( ស្រុកទេសចំរើនវឌ្ឍន៍ឡើងហើយ )

វដ្ដ ន.( មនុស្សកើតស្លាប់ក្នុងវដ្ដសង្សារ )

ក៏ និ.( វាក៏មានសេចក្ដីរីករាយ )

ក កិ.( គេកបង្កើតឲ្យមានល្បែងស៊ី-សង )

ក ន. (ផ្កៅពាក់ប្រឡៅនោក)

ករ ន. (លើកករប្រណម្យដាក់លើសិរសី)

---

## ១៧_ សត្វរៃនឹងស្រមោច

រៃជាសត្វខ្ជិល ដល់ហេមន្តរដូវកាលណា ក៏ហើរច្រៀងលេងតាមអំពើចិត្តខ្លួន ពុំគិតខ្វល់ខ្វាយនឹងរកស្បៀងអាហារទុកដាក់សំរាប់ខ្លួនឡើយ ៗ មានសត្វស្រមោចមួយជាសត្វឧស្សាហ៍ពាំនាំស្រូវអង្ករដាក់ក្នុងសំបុកខ្លួន គិតក្រែងក្តីក្រទៅមុខ ៗ

លុះដល់ភ្លៀងឧរដោតជាំមក . សត្វរៃនោះរកអាហារបរិភោគគ្មាន កើតក្តីឃ្លានបំណាំក្រៃពេក ទើបហើរទៅខ្ចីអង្ករស្រមោច ៗ ឯស្រមោចកាលបានឮរៃស្រដីអង្វរសូមខ្ចីស្បៀងដូច្នោះ ក៏សួរទៅថា ៖ អើរៃ ! កាលពីដើមឆ្នាំ

ខែប្រាំងកំពឹះនោះ តើហេតុម្តេចក៏អ្នកឯងមិនស្វែងរកអាហារទុកសម្រាប់ខ្លួន ។ រៃតបថា៖ សំឡាញ់អើយ ! យើងនេះពុំមានកិច្ចការអ្វីទេ រវល់តែហើរទុំលើឈើព្រៃស្រែកច្រៀងលេងតាមអំពើចិត្តប៉ុណ្ណោះ ។ ស្រមោចឆ្លើយថា៖ អើ ! បើពីដើមអ្នកឯងធ្លាប់ច្រៀងលេងយ៉ាងណា ឥឡូវនេះប្តូរអ្នករកទំនុកច្រៀងលេងទៀតទៅ ខ្ញុំឯងនឹងស្តាប់ផង ។

ឯរៃឮស្រមោចពោលចំអកដូច្នោះ ក៏ទាល់ប្រាជ្ញា ទើបហើរចេញពីទីនោះឆ្ពោះទៅកាន់លំនៅអាត្មា បានក្តីវេទនាដោយអត់អាហារស្រេកឃ្លាន តាមនិស្ស័យខ្លួនទៅ ។

គិត្ត (សុគន្ធប្រីជា)

ក- ពន្យល់ពាក្យ

ហេមន្តរដូវ : រដូវប្រាំងមានទឹកសន្សើមច្រើន ។

ខរ : បង្អុរ, ភ្លៀងធ្លាក់ ។

ខរដោកដាំ : ធ្លាក់ជាច្រើនសើមដោកដី ។

ពំនីរះ : ពំនីរធីស្ទុតឥតមានទុកដាក់ ។

តាមនិស្ស័យខ្លួន : តាមផលបុណ្យរបស់ខ្លួន ។

១- អក្ខរាវិរុទ្ធ

អាហារ (មាន រ ឯពិសាគ្មាន រ ទេ)

ហើរ (មាន រ នៅចុង)

ប្រៀង (សរសេរ ប មិនមែន ផ ទេ)

និស្ស័យ (ប្រយ័ត្នកុំសរសេរ និសៃយ)

គ- ពាក្យស័ព្ទ

ហោមន្ដរដូវ ឬ ហាមន្ដរដូវ ន. (រដូវប្រាំង)

សត្វ ន. (មនុស្សសត្វសឹងកើតក្នុងលោកដូចគ្នា)

សាត់ កិ. (ឈើសាត់មកតាមទឹកជំនន់)

សត្យ គុ. (មនុស្សសច្ចៈត្រូវកាន់ពាក្យសត្យ)

សត ន. (មួយសតវត្សមានមួយរយឆ្នាំ)

សត្ត គុ. (សត្តបរិតឈ្មោះធម៌មាន ៧ មេ)

រះ ប. (ថៃ្ងព្រាំងរាំងរះ)

បុស ន. (កាប់ឫស្សីដោយទាំងឫស)

និស្ស័យ ន. (ព្រះពុទ្ធមាននិស្ស័យជាអ្នកប្រាជ្ញ)

វិស័យ គុ. (កូននេះដូចឪពុកវាសុទ្ធវិស័យ)

---

## ១៩–វត្តមួយនៅស្រុកស្រែ

មានថ្ងៃមួយ, កាលខ្ញុំធ្វើការឯខេត្តសៀមរាប, មុខងារខ្ញុំបានចាត់ខ្ញុំឲ្យធ្វើដំណើរទៅកាន់ឃុំខ្នារ ដែលជាភូមិមួយនៅដាច់ឆ្ងាយពីទីប្រជុំជនកំពង់ក្តី គ្រាប់ទៅកាន់បានតែផ្លូវរទេះនិងផ្លូវដើរ កាត់ព្រៃដុនដែលសម្បូណ៌ទៅដោយខ្លា, ដំរី, ទន្សោង គ្រប់ព្រៃ និងប្រមឹគានានា ។

នៅផាយក្លូមិនេះ មានកូនវត្តមួយ ដែលទាញចក្ខុវិញ្ញាណយើងពុំដែលដាច់ ព្រោះជាទីឋានមួយដែលមានទឹកមុខញញឹមស្រស់ អាចធ្វើឲ្យសេចក្តីអផ្សុកនឿយហត់ទាំងប៉ុន្មានរលាយទៅបាន ៗ ប្រឡប់ខឿនខាងមុខវត្ត មានដើមដូងដុះជាជួរស្មើគ្នា យោលឆាងចុះឡើងទៅបបោសអង្អែលដំបូលកុដិស្បូវតូច ៗ ដែលជ្រកនៅខាងក្រោម មានសណ្ឋានដូចជាមាតាអង្អែលថ្នាក់ថ្នមបុត្រ ៗ

នៅផ្ទៃផែនដី ដែលបោសស្អាតរលីងរលំ ហើយដែលលំអទៅដោយពណ៌បៃតងនៃស្មៅកាត់តម្រេ មានកូនមាគ៌ាតូច ៗ ដែលគេសំអាតមិនឲ្យមានហ្មង សម្រាប់ជាគមនាគមន៍ទៅកុដិ, សាលា, ព្រះវិហារដែលមិនមានដំកើងបុកអ៊ុឡើយ ដោយធ្វើសុទ្ធតែពីឈើទាំងស្បូវប៉ុណ្ណោះ ប៉ុន្តែសុទ្ធតែជារបស់ស្អាតមានសុរិលទាំងអស់ ៗ

ឡូ-ហាប

ក- ពន្យល់ពាក្យ

គ្រាច់ទៅកាន់ៈ ធ្វើដំណើរទៅកាន់ ។

ព្រៃដុង. ព្រៃស្តុក, ព្រៃជ្រាស់ ។

ម្រឹគាៈ សត្វជើងបួនដែលរស់នៅដោយព្រៃ ។

ចក្ខុវិញ្ញាណ ៈ វិញ្ញាណដឹងដោយមើលឃើញ ។

គមនាគមន៍ៈ ការដើរទៅ-ដើរមក ។

មាគ៌ា ឬ មគ្គា ៈ ផ្លូវដើរ (Voie) ។

មានសុរិលៈ មានរូបពង់, មានអង្គកាយ (ឥតមន្ទិល) ។

ខ- អក្ខរាវិរុទ្ធ

ង៉ារ (មុខងារ, ងារសក្តិ មាន រ នៅចុង)

គ្រាច់ (សរសេរ គ្រេច ក៏បាន)

កុដិ (សរសេរ កុ ប្រកបនឹង ដ ស្រះ អិ)

ហ្វូង (សរសេរ ហ ដាក់ជើង វ)

គ- ពាក្យស័ព្ទ

ផារ ន. (លោកគង់មានផារជាម៉ឺនភក្តិ)

ផា កិ. (ផាអាវុធកាប់សត្រូវ)

ផាវ ន. (ភ្លូរបានដីមួយផាវ)

ឫក ន. (ស្រីនេះមានឫកពាសួតបូត)

ឫក្ស ន. (ថ្ងៃនេះមានបក្សពារដោតង័យល្អ)

ព្រាស កិ. (ក្មេងស្រីហែសសម្រាម)

ព្រោះ ន. (ពោះបានពោលទៅដី)

---

## ២០ - ពេលវេលាជាទ្រព្យវិសេស

មនុស្សដែលច្រើនតែនិយាយថា ខ្ញុំនមានពេលតិចពេក មិនអាចរៀនអ្វី ៗ បានទេ វល់តែធ្វើការផាវចិញ្ចឹមជីវិត ,

គិតគូរដូច្នេះមិនត្រូវទំនងសោះ ព្រោះមនុស្សកើតមកក្នុងលោកនេះ គ្មាននរណាធ្វើការតាំងពីពេលក្រោកពីដេករហូតដល់ពេលដេកវិញទេ ។ មនុស្សគ្រប់រូបតែងមានពេលដេក, ដើរ, ឈរ, អង្គុយ, ធ្វើការ, សំរាក, បរិភោគជាដើម ។

ដូច្នេះ ត្រូវយើងគិតថា ពេលទំនេរជាឱកាសសំខាន់បំផុតសំរាប់សេចក្តីចំរើនរបស់ជីវិតយើង ។ មានអ្នកធ្លាប់គិតលេខមើលឃើញថា: ការអានសៀវភៅល្អ ៗ ត្រឹមមួយថ្ងៃដប់ប្រាំនាទី, ក្នុងរយៈវេលាបួនឆ្នាំកន្លងទៅ នឹងទៅជាអ្នកមានការសិក្សាល្អមួយបាន គំនិតគិតគូរក៏ដុះអណ្តែតខ្ពស់ឡើងច្រើន ។ ព្រោះការបណ្តុះវិជ្ជាផ្សេង ៗ ដែលខ្លួនស្ម័គ្រចិត្តចង់រៀនសូត្រ ឲ្យបានល្អគួរសមចំរើនពេញលេញល្អ មិនមែនជាប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាងទេ គឺជាបច្ច័យឲ្យប្រទេសជាតិចំរើនឡើងទៀតផង ។

ញ៉ុក-ថែម

ក- ពន្យល់ពាក្យ

ទ្រព្យវិសេស : សម្បត្តិដ៏បំណាន, ដ៏មានដម្លៃ ។

នាទី : (ទីនេះ) កម្រិតពេលតូចជាងម៉ោង ៦០ ដង(Minute)

រយៈវេលា : រយៈពេល, កំណត់ពេល ។

បច្ច័យ : ហេតុផលដ៏កនាំឲ្យបានដល់អ្វីមួយ ។

ប្រទេសជាតិ : ប្រទេសរបស់ខ្លួន ប្រទេសកំណើត ។

១- អក្ខរាវិរុទ្ធ

បំពុំម (សរសេរ ញ ជើង ប ស្រៈ អឹ)

ទំនេរ (មាន រ នៅខាងចុងបំផុត)

សំពក (ឥតមានស្រៀសញាទេ)

សំពប់ (មានស្រៀសញាលើ ប)

រយៈវេលា (ត្រូវមានយុគលពិន្ទុពីមុខ យ)

ស្ងំគ្រ (សរសេរមានសំយោគសញាប្រកបនឹង គ្រ)

ម្យ៉ាង (ត្រូវមានមូសិកទន្តលើជើង យ)

បច្ច័យ (សរសេរ ច ជើង ច សំយោគសញ្ញា)

គ- ពាក្យស័ព្ទ

អាន កិ. (មើលសៀវភៅហៅថាអានសៀវភៅ)

អាន ន. (គេបងអានឲ្យសេះរួចទើបលោតឡើង)

ចិត្ត ន. (ត្រូវមានចិត្តស្មោះនឹងប្រទេសជាតិ)

ចិត កិ. (ចិតត្រសក់មកជ្រលក់ទឹកគ្រឿង)

សូត្រ កិ. (លោកសង្ឃសូត្រធម៌)

សូត្រ ន. (គេចិញ្ចឹមនាងធ្វើសូត្រ)

សូត្រ ឬ សូត្ត ន. (ធម្មកថិកសម្ដែងធម៌ពីព្រះសូត្រ)

---

## ២១- កំពង់ចាម

កំពង់ចាម ជាអាណាខេត្តចំបងនៃប្រទេសកម្ពុជា ខាងការចំរើនផលានុផល ។

ទីប្រជុំជន ឬ ទីរួមខេត្តកំពង់ចាម តាំងនៅជាប់ទីមាត់ទន្លេមេគង្គត្រើយខាងលិច ដ៏មានមនុស្សកុះករស្ថិតនៅជាច្រើនជាតិ ច្រើនសាសន៍ ។ វិថីខ្វាត់ខ្វែងកាត់ទីប្រជុំជនសំរាប់បង្ហាញទេសចរទាំងឡាយ ឲ្យឃើញច្បាស់នូវផលនារបស់បណ្ដាជនក្នុងតាណាខេត្ត ។ របៀបរៀបចំក្រុងនេះមានសណ្ឋានប្លែកជាជាងក្រុងដទៃ ហាក់ដូចជាអ្នករៀបចំបន្ទុកស្នាដៃចំឡែកឲ្យផ្សេងពីគេ ។ ផ្លូវទាំងឡាយមិនមែនបែងជាក្រឡាចត្រង្គស្មើគ្នាទេ គឺមានញែក - រង្វើលតាមក្បាច់របនាដែលបែងចែកពីដើមផ្លូវតែមួយបីដូចជាផ្កាដែលគេឈាតត្រដាង ។ ក្នុងផ្សារ, មានជនលក់ផលានុផល ដែលកើតក្នុងស្រុកគ្រប់បែបយ៉ាងពុំមានខ្វះ ។

ក្រៅពីការចំរើនផលានុផល កំពង់ចាមជាខេត្តមួយចំរើនខាងវប្បធម៌លើសលែងខេត្តនានាក្នុងគ្រាបច្ចុប្បន្ននេះ ។ ឯការវប្បធម៌របស់បណ្ដាជនក៏កាន់តែមានវិវឌ្ឍនាការលើសកាល

ពីដប់ឆ្នាំមុនសន្ធឹកណាស់ ។ វិទ្យាល័យមួយដែលស្ទួយ ជាប់ព្រះបរមនាមនៃព្រះបិតាឯករាជ្យខ្មែរ ជាមជ្ឈដ្ឋានផ្សាយនូវវប្បធម៌ដ៏ក៏ស្កានដល់យុវជនគ្រប់ខេត្តនេះ ។

លី-ធាមតេង

ក-ពន្យល់ពាក្យ

ផលានុផល : ផលផ្សេងៗ, ផលសព្វសារពើ ។

ចលនា : ការរស់រវើក, ការកំរើកជានិច្ច(mouvement) ។

ក្រឡាចតុរង្គ : ក្រឡាបួនជ្រុង, ក្រឡាមានជ្រុងបួន ។

វប្បធម៌ : ការចំរើនខាងប្រាជ្ញា, ការបណ្ដុះក្បួនច្បាប់(culture)

អារ្យធម៌ : ការចំរើន, សេចក្ដីចំរើនថ្កុំថ្កើង(Civilisation) ។

វិវឌ្ឍនាការ : ការចំរើនឡើង (Progession) ។

វិទ្យាល័យ : សាលារៀនថ្នាក់មធ្យមសិក្សា(Lycée) ។

ព្រះបិតាឯករាជ្យ : គឺជាអគ្គសម្ដេចព្រះឧបយុវរាជ ន.សីហនុ។

មជ្ឈដ្ឋាន : ទីជាកណ្ដាល, កន្លែងកណ្ដាល ។

១- អក្ខរាវិរុទ្ធ

កុះកុំ (កុំសរសេរ កុសកុំ ឬ កុះកំ)

នានា (កុំសរសេរ នា ៗ)

សន្ទឹក (សរសេរ ជើងធ ស្រៈអឹ)

ខេត្ត ឬ ខែត្រ (សរសេរបានទាំងពីរបែប)

គ- ពាក្យស័ព្ទ

កំពង់ ន. (គេចុះទៅកំពង់ដងទឹក)

កំពុង កិ. (គេកំពុងធ្វើការ)

ភជ្ឈ ន. (ព្រះច័នសំរាប់ភជ្ឈ)

ភជ· ន. (ត្របហោងចេញពីភជភំង)

ផ្សារ ន, (ស្ត្រីម្នាក់ទៅផ្សារទិញត្រី)

ផ្សារ កិ. (ជាងផ្សារប៉ោតឲ្យជិត)

ផ្សា គុ (ដំបៅនេះឈឺផ្សាណាស់)

# ២២-វិបត្តិវប្បធម៌ខ្មែរ

ក្នុងគ្រានាយកលើស្រុកខ្មែរ សៀមប្រមូលយកទៅចំរើនស្រុកសៀមអស់ទាំងគម្ពីរក្បួនខ្នាតនានា នឹងចំណេះវិជ្ជាផ្សេង ៗ ។ ជាន់នោះ ដោយសាបអំណាចយសសក្តិ ខ្មែរក៏បោះបង់ចោលវិជ្ជាគ្រប់ប្រការ ទោះរបស់នោះល្អវិសេស ដូចជាប្រាសាទសិលានៅទីក្រុងអង្គរ ក៏ចោលឥតស្តាយស្រណោះឡើយ ។

កាលនៅក្នុងគ្រាអាប់ចុះ ខ្មែរប្រុសដែលចេះអក្សរល្មមមើលសំបុត្របាន មានប្រហែលបីនាក់ប៉ុណ្ណោះ ក្នុងចំនួនដប់នាក់ ។ ឯស្រី ៗ វិញបោះបង់ចោលលែងរៀនអក្សរទាល់តែសោះ ។ កាលបើគេរើសជំរេះ, នៅវេលាផ្សំផ្គុំបុត្រាបុត្រីជាគូស្រករ, គេគ្រាន់តែសួរគេជំរេះខាងរកស៊ី គឺឲ្យចេះកាប់សង្រែក បតត្នោត ត្បាញល្អ ៗ ឯនឹងរើសគេស្ត្រី

ជាក្រិយាវិញ ស៊ើបសួររកនាងណាចេះដេរប៉ាក់, ចេះការត្បាញរវៃ, ចេះដណ្ដាំស្លប៉ុណ្ណោះ ទុកជាការប្រសើរ ។

ខ្មែរយើង ទើបតែស្រើបចិត្តស្វែងរកចំណេះវិជ្ជាទៀតវិញ ពីត្រឹមរជ្ជកាលព្រះបាទព្រះហរិរក្សរាមាធិបតីព្រះអង្គឌួង ។

ពូរ - អ៊ុម

ក- ពន្យល់ពាក្យ

នាយកលើ: ជាធំលើ, ជាចៅហ្វាយលើ ។

ប្រាសាទសិលា: ប្រាសាទថ្ម ។

គ្រាអាប់ចុន: គ្រាដុនដាប, គ្រាថោកទាប ។

បុត្រីបុត្រា: កូនស្រី-ប្រុស ។

ស្រើបចិត្ត: ភ្ញាក់ក្នុងចិត្ត, នឹកឃើញក្នុងចិត្ត ។

រជ្ជកាល: សម័យរបស់ព្រះរាជាគ្រងរាជ្យ (Règne) ។

ខ- អក្ខរាវិរុទ្ធ

សិលា (សរសេរ ស ស្រៈអកុំប្រែទៅសីលា)

ផ្សំផ្គុំ (ផ្សំស្រៈអំ ឯផ្គុំស្រៈអុំ)

គូស្រករ (មាន រ នៅចុង)

ស្វ (ឥតមាន រ នៅចុងទេ)

រដ្ឋកាល (សរសេរ ដ ជើង ឋ)

គ- វាក្យស័ព្ទ

អាប់ គុ. (បាញ់គេទាល់តែអាប់មុខ)

អ័ព្ទ ន. (ព្រឹកមិញមេឃចុះអ័ព្ទសន្ធឹកណាស់)

អព្ភ គុ. (ការនេះនាំឲ្យអព្ភបញ្ញា)

សួរ កិ. (ខ្ញុំសួរទៅកាន់ប្អូនខ្ញុំថា ...)

សួ កិ. (ខ្ញុំឡើងសួលើមែកឈើ)

សួគ៌ ន. (ទេព្ដាកើតនៅស្ថានសួគ៌)

បិត កិ. (គេអង្គុយបិតផ្ដៅ)

បិទ កិ. (គេទាញទ្វារបិទឲ្យជិត)

ប៉ាក់ កិ. (ស្រីនេះប្រសប់ដេរប៉ាក់ណាស់)

បក្ស ឬ បក្ខ ន. (កុំនិយាយប្រកាន់បក្សពួក)

---

## ២៣–ក្អែកបិត្តលោភ

មានក្អែកគោកមួយ អាស្រ័យនៅក្នុងដងព្រៃមួយអន្លើ ដោយក្អែកមេជាភរិយា ។ ថ្ងៃមួយចៅបក្សាណានាំភរិយាចេញទៅរកអាហារតាមដោយមាត់បឹង ។ លុះទៅដល់បឹងមួយ បានឃើញហ្វូងក្អែកទឹកទីងស្មោញទាំងឡាយ ហែលមុជចាប់ត្រីបានបរិភោគរៀងខ្លួន ។ ក្អែកនោះគិតថា ក្អែកទាំងនេះ ក៏ជាបក្សីដូចអញដែរ ហេតុអ្វីក៏គេមុជចាប់ត្រីបាន អញសោតជាក្អែកដូចគេដែរ គួរខ្មាសគេណាស់ ។ បើដូច្នេះ គួរតែអញចុះមុជចាប់ត្រីទីងគេឲ្យបានអាស្រ័យ កុំឲ្យគេមើលងាយបាន ។

គិតហើយក្អែកគោកសំឡុបស្លាប មុជទឹកធ្វើញាការ
ដូចក្អែកទឹក ខំប្រឹងមុជទៅប៉ះសាពយណែនណាន់ ពន្ធក
ក្អែក ស្រោបកាយ រុំព័ន្ធព្រាណ ។ ក្អែកខ្លួនពុំបាន
ឈ្មក់ទឹកដល់នូវមរណកាលកណ្ដាលគង្គាក្ដីគ្រានោះទៅ ។

គង្គ (សុគន្ធប្រីជា)

ក- ពន្យល់ពាក្យ contraire au

ក្អែកគោក: ក្អែករកស៊ីលើគោកផ្ទុយពីក្អែកទឹក ។

ដងព្រៃ: ផ្លូវព្រៃ, ដំបន់ព្រៃ ។

មួយអន្ទើរដោយ: ជាមួយនឹង, មូលមួយគ្នានឹង ។

ក្អែកមេ: ក្អែកញី, មេក្អែក ។

អាស្រ័យ: បរិភោគ, ស៊ី ។

សំឡុបស្លាប: សង្រួមស្លាប, ដាក់ស្លាបមកជិតខ្លួន ។

មរណកាល: ពេលស្លាប់, សេចក្ដីស្លាប់ ។

កណ្ដាលគង្គា; កណ្ដាលផ្ទៃទឹក ។

ខ- អក្ខរាវិរុទ្ធ

អាស្រ័យ (ប្រយ័ត្នកុំសរសេរ អាស្រៃ)

បឹង (សរសេរស្រៈ អឹ)

ហ្វូង (សរសេរដូចនេះ តែអានថា វ៉ូង)

មុជ (សរសេរ មុ ទឹង ជ មិនមែន ច ទេ)

សំឡប ឬ សម្លប (ដាក់បានទាំងពីរយ៉ាង)

អាការ (សរសេរ រ នៅខាងចុង)

ប៉ះ (ប្រយ័ត្នកុំសរសេរប៉ាស់ ឬប៉ាះ)

គង្គា (ប្រយ័ត្នកុំសរសេរគុង្គា)

គ- ពាក្យស័ព្ទ

ព័ន្ធ កិ. (កុំបេករឿងគេមកព័ន្ធដៃព័ន្ធជើង)

ពាន់ សំ. (ខ្ញុំមានប្រាក់ប្រាំពាន់រៀល)

ពន្ធ ន. (បណ្ដារាស្ត្របង់ពន្ធឲ្យរាជការ)

ពន់ គុ. (គេកើតទុក្ខពន់ពេកណាស់)

គ្រា ន. (គ្រាណាខ្ញុំត្រូវឆ្នោត ខ្ញុំនឹងទិញផ្ទះមួយធំ)

គ្រាហ៍ កិ. (អ្នកជំងឺសុទ្ធតែជួយគ្រាហ៍ទើបដើររួច)

---

## ២៤-វត្តស្រុកស្រែ

នៅក្បែរព្រះវិហារ មានទេវស្ថានបុរាណមួយសង់ពីថ្មបាយក្រៀម ដែលបាក់បែកដោយជរាភាពណាស់ទៅហើយ ។ នៅបរិវេណនៃស្ថាននេះ មានទេវរូបនិងបដិមា ខ្លះដាច់ព្រះសិរ ខ្លះបាក់ព្រះហស្តនិងព្រះបាទ រប៉ាត់រប៉ាយ ហាក់ដូចជាបេះពោលប្រាប់យើង អំពីអំពើអាក្រក់នៃជនសែយសាសន៍ ។

ពេលដែលខ្ញុំចេញពីវត្តនេះទៅ ព្រះសុរិយាក៏បន្ទាបផិតអស្តង្គត បញ្ចាំងរស្មីទៅលើជញ្ជាំងក្តារឲ្យក្រព្រាត ៗ ។ ឯសំឡេងព្រះសង្ឃដែលស្វាធ្យាយធម៌ ក៏ឮរងំកប់ទីនមាត់មាន

ព្រៃទឹងតាពៅ ដែលនាំគ្នាស្រែកហោចំពោះព្រះអាទិត្យ ។ បន្តិចក្រោយមក សូរព្រះធម៌នេះ នៅតែមានអណ្ដែតក្នុងផ្ទៃរាត្រីងងឹតសូន្យ គឺរាត្រីស្រុកព្រៃដែលស្ងាត់ជ្រងំ ហើយដែលក្លិនផ្កាស្រទៀត ឬ ផ្កាព្រហ្មផាត់ក្រអូបភាយ ៗ បណ្ដាក់គ្នានឹងសម្រែកខ្លា, សម្រែកដំរី ដែលចេញដើរស្វែងរកអាហារ ។

ដោយវត្តនេះ មានរៀបសំអាតឥតមានមន្ទិល ទីង ដោយតាំងនៅកណ្ដាលទ្រូងអរញ្ញ ឃ្លាតឆ្ងាយពីសេចក្ដីក្រេកត្រអាលនៃមនុស្សជាតិនោះ អ្នកដំណើរទាំងឡាយក៏ភ្ញាក់យល់ក្នុងចិត្តថា ទីនេះសមជាទីអាស្រមបំពេញសីល-ទាន ប្រកបតាមពុទ្ធោវាទឲ្យបានហ្មត់ហ្មង់ពុំខានឡើយ ។

ឌូ - ហាប

ក- ពន្យល់ពាក្យ

ទេវស្ថានបុព្វណា : កេងទេវតាសង់តាំងពីដើម ។

បរិវេណា : ទំហំដែលមានកំណត់របងព័ទ្ធជុំវិញ ។

ពុទ្ធបដិមា : រូបសំណាកជាអង្គព្រះពុទ្ធ, ពុទ្ធរូប ។

ព្រះសិរ : ក្បាល, សិរសា, ព្រះកេស ។

សៃយសាសន៍ : សាសន៍ដទៃ ។

ជិតអស្តង្គត : ជិតលិចរស្មីទៅខាងលិច ។

អរញ្ញាវា : ដងព្រៃ, ទ្រូងព្រៃ, ព្រៃជ្រៅ ។

ពុទ្ធោវាទ : ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

១- អក្ខរាវិរុទ្ធ

ក្បែរ គុ. ( មានរនៅចុង )

ក្រៀម គុ. ( សររសេរក ជើង រ )

សិរ, សីរ, សេរ ន. (ដាក់បានទាំងបីយ៉ាង)

ជ្រូនំ គុ. (សរសេរ ន ស្រៈ អំ)

សីលទាន ន. (សរសេរ ស ស្រៈ អី)

គ – ពាក្យស័ព្ទ

ស្ងួរ ន. (គេឮស្ងួរថ្លៃលួនៅកណ្ដាលយប់)

ស្ងួរ ន. (ព្រះស្ងួរៈខ្ពស់ណាស់ហើយ)

ស្ងួ ន. (ក្មេងនេះពាក់ខ្សែស្ងួនៅក)

---

## ២៥– ពុទ្ធសាសនានិងវិទ្យាសាស្ត្រ

បណ្ដាចំណេះវិទ្យាសាស្ត្រដែលពុទ្ធសាសនា ត្រូវតែនាំមកពន្យល់នៅទីចំពោះមុខនៃប្រជុំជនទំនើបស្ដាប់ ទើបយល់សេចក្ដីនៃវិជ្ជាទាំងពីរច្បាស់ណាស់ ។ ប៉ុន្តែបើតាមយោបល់របស់អ្នកប្រាជ្ញគង់គ្រួសម្នាក់ បានតែងសៀវភៅមួយនិយាយពីប្រវត្តិរបស់ព្រះពុទ្ធ ហៅថា "ប្រទីបទ្វីបអាស៊ី" ។

សៀវភៅនេះនិយាយពីគោលសំខាន់ៗ នៃព្រះពុទ្ធសាសនា ទាំងយោបល់និងគំនិតគិតឃើញ ជារបស់អ្នកនៅទិសខាងលិច ។ កាលបើគេបានជ្រួតជ្រាបលទ្ធិពុទ្ធសាសនាហើយ ក៏អាចរលាយចូលគ្នាបាននឹងលទ្ធិយោបល់ របស់អ្នកនៅទិសខាងកើតបាន ។ ហើយក្លាយទៅជាវិជ្ជាចំណេះរបស់អ្នកនៅទិសខាងលិចទៅវិញ សេចក្ដីពិតមិនមែនសោះឡើយ ។ ព្រោះសាសនាមិនមែនជាវិទ្យាសាស្ត្រទេ គ្រាន់តែជាគោលសិក្សា ព្រមទាំងការប្រតិបត្តិដោយម៉ឺងម៉ាត់ ដើម្បីធ្វើជីវិតរបស់មនុស្សឲ្យប្រព្រឹត្តទៅបានស្រួលប៉ុណ្ណោះ ។

ញ៉ុក-ថែម

ក- ពន្យល់ពាក្យ

ពុទ្ធសាសនា: ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

វិទ្យាសាស្ត្រ: ក្បួនច្បាប់វិជ្ជា, វិជ្ជារិះរក, វិជ្ជាស្រាវជ្រាវ

ប្រវត្តិ: សាវតារ, រឿងរ៉ាវសាវតាកំណើត ។

អ្នកនៅទិសខាងលិច : (Pays Occidental) ។

អ្នកនៅទិសខាងកើត : (Pays Oriental) ។

ប្រទីបអាស៊ី : (La lumière de l'Asie) ។

គោលសិក្សា : ទ្រឹស្ដី (Théorie) ។

ការប្រតិបត្តិ : ការអនុវត្តន៍ (Application) ។

ខ - អក្ខរាវិរុទ្ធ

ក្លាយ (សរសេរ ក ជើង ល )

មុឹងម៉ាត់ ឬ ហ្មឹងហ្មាត់ (ដាក់បានទាំងពីរបែប)

ជីវិត (សរសេរ ជ ស្រៈ អី, វ ស្រៈ អិ)

គ–ពាក្យស័ព្ទ

សាស្ត្រ ន.( វិទ្យាសាស្ត្រ, អក្សរសាស្ត្រ )

សាសន៍ ន.( សាសន៍ខ្មែរ. សាសន៍ចិន )

សះ កិ.( ដំបៅដាសះមែនទែនហើយ )

កើត ន.( ព្រះអាទិត្យរះខាងកើត )

កើត ន. ( ថ្ងៃនេះជាថ្ងៃ៣កើតខែបុស្ស )

កើត កិ. ( ស្ត្រីនេះទើបកើតបានកូនមួយ )

ប្រតិបត្តិ ន. ( រាជការដាក់ច្បាប់ឲ្យរាស្ត្រប្រតិបត្តិ )

ប្រណិបតន៍ ន. (សិស្សត្រូវប្រណិបតន៍គ្រូអាចារ្យ)

---

## ២៦ – ទឹកឈូ

ហ៊ូ ! ហ៊ូ ! ហ៊ូ ! មិនដាច់សូរ ។ សន្ទឹកព្រឹក្សាមិនមានកម្រើកឡើយ ។ ទេសភាពជិតខាងស្ថិតក្នុងសភាពស្ងប់ស្ងៀមដូចត្រូវស្រណ្ដាំ ។ មេអំបៅលឿង, ស, ក្រហមតាំងហ្វូងនាំគ្នាហើរវិលវើកតាមចន្លោះផ្កា ។ សត្វស្លាបចេកហ្វូងបក្សធ្វេក ៗ ក្នុងគុម្ពដើមគគ្គា ។ កំពូលភ្នំពណ៌ផ្ទៃមេឃខ្ចី នៅឯឆ្ងាយមើលទៅឃើញលិមៗ ។ ទឹកហូរចេញពីជ្រោះភ្នំ បង្កើតជាអូរដែលមានតែដណ្ដើរធម្មជាតិកើតឡើងដោយការតម្រៀបមិនត្រឹមស្មើនៃដុំសិលា ។

ឱទឹកហូរអើយ ! អ្នកមានដើមកំណើតមកពីណា ... ជាទេពនិមិតទេដ៏ដែលបណ្ដាលឲ្យអ្នកត្រជាក់ស្រិបដូច្នេះ ។ អ្នកដំណើរតែងនាំគ្នាបណ្ដែតកាយលេង ឬ វារចុះវារឡើង ហើយក្អាកក្អាយ (សែនក្រេមក្រានក្នុងចិន្ដា) ហាក់បីដូចជាហ្វូងកិន្នរកង្គំនូរដែលកំពុងតែលេងទឹក អនោតស្រះនៃស្ថានកៃលាស ។

ឈូ ! ឈូ ! សូរទឹកហូរគ្មានអាក់ សមនឹងឈ្មោះថា «ទឹកឈូ» មែន ។

អ៊ឹម - ឈូដេត

ក— ពន្យល់ពាក្យ

ទេសភាព: សភាពរបស់ស្រុក (Paysage) ។

ដើមគគ្គា : ឈ្មោះដើមឈើមួយគេយកតាំងជាលំអរ ។

ដំណើរធម្មជាតិ : ដំណើរដែលកើតឯង ។

ទេពនិមិត : ទេវតាកាឡា ឬទេវតាដំណែង ។

ក្រៀមក្រាន្តក្នុងចិន្តា : សុខសាន្ត ឬ រីករាយក្នុងចិត្ត ។

អនោតស្រះ : ឈ្មោះស្រះធំមានទឹកត្រជាក់មិនចេះត្រូវ

កំដៅ ។

ស្ថានកៃលាស : ឈ្មោះភ្នំពិសេសមួយក្នុងចំណោមភ្នំ

ហិមពាន្ត ។

១- អក្ខរាវិរុទ្ធ

កម្រើក ឬ កំរើក (សរសេរបានទាំងពីរយ៉ាង)

ស្ថិត ឬ ឋិត (សរសេរបានទាំងពីរយ៉ាង)

គុម្ព (សរសេរ ម ជើង ព)

ស្បូរ (មាន រ នៅចុង)

វារ (មាន រ នៅចុង)

ក្រៀមក្រាន្ត (កុំសរសេរខ្សៀមខ្សាន្ត)

កិន្នរ (ប្រយ័ត្នកុំសរសេរកេណរ ឬ កិណ្ណរ)

គ- ពាក្យស័ព្ទ

សិលា ន.( ទឹកហូរបោកលើដំសិលា )

សីលា ន.( សីល ) (តាបសឫសីកាន់សីលា )

កាយ ន.( គេបណ្តែតកាយលេងតាមទឹក )

កាយ កិ.( គេកាយដីចេញពីរណ្តៅ )

អាក់ កិ ( ទឹកហូរគ្មានចេះអាក់ )

អាក់ ន.( គេការសូត្រដាក់ក្នុងអាក់ )

---

## ២៧ _ ផលប្រយោជន៍នៃផ្លូវទឹក

ដោយភូមិស្រុកខ្លះនៅតាមមាត់ទន្លេដែលមិនមានដីគ្រើយជាប់គ្នា ទន្លេក៏ជាផលមគ្គ ឬ ជាគមនាគមន៍សំរាប់ធ្វើដំណើរប្រសើរលើសលប់មួយដែរ ។ ក្នុងរដូវវស្សាទឹកទន្លេឡើងពោរពេញលំហារ បណ្តាលឲ្យហូរបង្កើតជាល្បឿន

លោកទឹកយ៉ាងខ្លាំង ។ ទឹកហូរទន្លេលោកដែលជួបទៅប្រាំង ទន្លេ ព្រោះដីតាមមាត់ប្រាំង ក្លួចយកទៅបាតទន្លេកើតជា គម្របល្អក់ស្អុតខៃផ្សែងៗ ។ កករទឹកនេះ គេហៅថាល្បាប់ ដែលទន្លេនាំមកចាក់នៅញមឃ្នុំនៅមាត់ប្រាំង, មាត់ព្រែក ក្នុងវេលាទឹកជំនន់ឡើងខ្លាំងមក ។ ដីល្បាប់នេះឯងជាដីជាតិ ប្រសើរក្រៃលែងចំពោះផលដំណាំក្នុងចំការនានា ដែលនៅ ក្បែរមាត់ទន្លេ ។

ត្រីដែលជាអាហារសំខាន់របស់យើងក៏កើតមកដោយ សារទឹកទន្លេដែរ ។ រាល់ៗឆ្នាំ អ្នកនេសាទបានចាប់ត្រីពី ក្នុងទន្លេទាំងនេះរាប់ម៉ឺនសែនក្បាល លក់ចំណាយទៅគ្រប់ ទិសទីក្នុងប្រទេសនិងក្រៅប្រទេសទៀត ។ ក្រៅពីនេះ ទន្លេអាចផ្ដល់ទឹកឲ្យអ្នកធ្វើចំការបញ្ជូរដំណាំយើង បានផលគ្រប់ គ្រាន់ផង ។

ហេតុនេះ ទន្លេជាផលប្រយោជន៍យ៉ាងចំណានរបស់ប្រទេស ។

ណាង - ហាប់អាន

ក - ពន្យល់ពាក្យ

ជលមគ្គ : ផ្លូវទឹក, ជលធារ (Cour d'eau) ។

គមនាគមន៍ : ការធ្វើដំណើរទៅ - មក (Communication) ។

រដូវវស្សា : រដូវទឹកជំនន់, រដូវភ្លៀង (Saison de pluie)

ពាម : កន្លែងមាត់ព្រែក, ទីមានព្រែកភ្ជាប់នឹងទន្លេ ។

១ - អក្ខរាវិរុទ្ធ

ពោរពេញ (មាន រ នៅពីមុខ ពោ)

លំហារ (មាន រ នៅខាងចុង)

ហូរ (មាន រ បើហៅគ្មាន រ ទេ)

កួប (សរសេរ ក ស្រៈ អួ)

ម៉ដ្ឋ (ប្រយ័ត្នកុំសរសេរម៉ត់)

ជោរ (មាន រ នៅចុង)

ជីជាតិ (ឥតមាន រ ទេ)

ដោយសារ (មាន រ នៅចុង)

ច្បារ (មាន រ , កុំច្រឡំផ្កាច្បា)

គ- ពាក្យស័ព្ទ

ប្រាំង ន. (ប្រាំងមាត់ទន្លេបោតណាស់)

ជ្រាំង ន. (ក្មេងកើតជ្រាំងពេញមាត់)

ច្រោះ កិ. (ទឹកច្រោះដីឲ្យហូរចេញអស់)

ជ្រោះ ន. (ទឹកស្ទឹងហូរមកពីជ្រោះភ្នំ)

ជី ន. (ដាំបន្លែស្រូវដាក់ជីផង)

ជីរ ន. (ចូរបេះស្លឹកជីរមកជ្រក់ត្រីស្ងោរ)

ជី ន. (ខ្សែដៃនេះទម្ងន់មាស៣ជី)

# ២៨- បុត្រីមានគុណធម៌

កម្មកររោងចក្រម្នាក់ នៅពោះម៉ាយ ជាយូរឆ្នាំមកហើយ ។ ប្រពន្ធគាត់ស្លាប់បាត់បង់ទៅទុកកូនស្រីមួយឲ្យបីថែរក្សា ។

ថ្ងៃមួយកម្មករនេះ កំពុងតែប្រកបការដូចគ្រាធម្មតា ស្រាប់តែគ្រឿងចក្រនោះផ្ទុះឡើង បណ្ដាលឲ្យមានគ្រោះថ្នាក់ដល់ភ្នែកគាត់ទាំងពីរ ងងឹតលែងមើលអ្វីឃើញតាំងពីថ្ងៃនោះមក ។ គាត់ត្រូវតែដើរធ្វើសូមយាចក ដើម្បីសុំនូវសប្បុរិសធម៌ពីជននានាសំរាប់ចិញ្ចឹមជីវិតគាត់ និងកូនស្រីគាត់នៅតូច ។ ពលថ្ងៃ កុមារីនេះ តែងនាំបិតាទៅដាក់ឲ្យអង្គុយកន្លែងណាដែលមានមនុស្សច្រើន ហើយខ្លួននាងលបទៅរៀនអក្សរឯសាលា មិនឲ្យឪពុកដឹងឡើយ ។ បុត្រីសេដ្ឋីឯទៀត តែងនាំគ្នាពោលដៀលត្មះនាងថា មេកូនអ្នកសុំទាន, តែនាងឥតឆ្លើយតបសោះ ។

ព្រឹកមួយនោះ ជាថ្ងៃប្រឡងវិញ្ញាបនបត្រ នាងបានដឹកដៃឪពុកពិការទៅដាក់កន្លែងសុំទានដូចសព្វដង រួចនាងប្រញាប់ប្រញាល់ទៅចូលប្រឡងជាមួយគេ ។ ប្រាំបីថ្ងៃក្រោយមក នាងបានទទួលលទ្ធផលល្អត្រកាល ហើយរត់ម្នីម្នាទៅរកឪពុក ។ នាងលោតទៅឱបកមនុស្សពិការ ហើយពោលថាៈ ពុក! ចាប់ពីថ្ងៃនេះទៅ យើងលែងសុំទានគេទៀតហើយ កូនទើបនឹងប្រឡងជាប់វិញ្ញាបនបត្រ ។ កូននឹងចេញធ្វើជាគ្រូយកប្រាក់ខែចិញ្ចឹមពុក កុំឲ្យពុកដើរសុំគេ, សៀកពាក់គណ្ដាប់ប្រៀកនៀតដូច្នេះទៀត ។

លី-ធាមតេង

ក-ពន្យល់ពាក្យ

កម្មករពេនចក្រ : អ្នកធ្វើការកងពេនម៉ាស៊ីន ។

សមយាចក : អ្នកសុំទាន, មនុស្សសុំទានគេ ។

សប្បុរសធម៌ : ធម៌សប្បុរស, សេចក្ដីសប្បុរស ។

វិញ្ញាបនបត្រ : ឈ្មោះសញ្ញាបត្រមួយយ៉ាង(Certificat) ។

លទ្ធផល : ផលដែលបានសំរេចជាបំផុត(Résultat) ។

ជ្រៀកជៀត : រហែករយ៉ែដូចជាធ្វើជៀតគ្រី ។

ខ– អក្ខរាវិរុទ្ធ

ដៀលត្មះ : (កុំសរសេរ ដៀលត្មិះ ឬ ដៀលថ្មាស)

បិតា : (ប្រយ័ត្នកុំច្រឡំ សរសេរ បីតា ឬ បីដា)

ប្រៀកជៀត : (សរសេរ ប ជើង រ)

គ – វាក្យស័ព្ទ

បក្រ ន. ( នាវាសម័យប្រើសុទ្ធតែគ្រឿងបក្រ )

ចាក់ កិ. ( អញ្ជើញគ្រូពេទ្យមកចាក់ថ្នាំ )

ច័ក្ខុ (អ.ថ.ចាក់) ន. ( ព្រះឥន្ទ្រាបើកទិព្វច័ក្ខុ )

រត់ កិ. ( ក្មេងរត់ប្រណាំងគ្នា )

រតន៍ ឬ រត្ន ន. ( រតន៍ប្រែថាពេជ្រ ឬ កែវ )

រដ្ឋ ន.( ខ្ញុំនៅក្នុងរដ្ឋកម្ពុជា )

រថ ន.( ព្រះរាជាគង់លើរថទឹមសេះ)

---

## ២៩_ ខួរក្បាល

ខួរក្បាលជាសាច់ទន់ភ្លន់ល្វៃ ប្រហែលនឹងសាទ៌ផុរេន យ៉ាងធំ មានទំហំតូចជាងក្បាលរបស់ម្ចាស់ខ្លួនបន្តិច មានទម្ងន់ប្រមាណមួយពាន់ប្រាំរយក្រាម ។ ឯខ្នាតខួរក្បាលធំ ឬ តូច មានទម្ងន់ធ្ងន់ ឬ ស្រាលមិនមែនជាគ្រឿងវាស់សេចក្ដីល្ងង់ខ្លៅឆ្លៀវឆ្លាតទេ ព្រោះមនុស្សមានក្បាលធំ មានខួរច្រើន តែជាមនុស្សល្ងង់ខ្លៅក៏មានគួរគោត ។ ឯសេចក្ដីល្ងង់ឆ្លាតនៅត្រង់សាច់របស់ខួរក្បាលដែលមានសណ្ឋានល្អ ឬ អាក្រក់មកពីកំណើត ។ ហេតុនេះទើបឃើញថា ខួរក្បាលល្អមានទំនងដូចសំពត់សាច់ម៉ដ្ឋប្រើជាប់បានយូរ ។

ខួរក្បាលនេះ ជាអវយវៈសំខាន់បំផុតរបស់រាងកាយ ជាអធិបតីស្តីការលើសរីរយន្តទាំងពួងក្នុងរាងកាយ មានទំនងដូចមន្ត្រីស្តីការក្នុងក្រសួងនីមួយ ៗ ដែរ ។ ប្រសិនបើខួរក្បាលពិការទៅ ឬ អធិបតីនោះស្តីការមិនត្រឹមត្រូវ មុខជាការងារទាំងពួងនឹងកើតរវឹកផ្តេសផ្តាស ទៅតាមគ្នាទាំងអស់មិនខាន ។ Tầm bậy - Tầm bạ

ញ៉ុក - ថែម

ក- ពន្យល់ពាក្យ

ល្ងន់ល្ងៃ : ដែលទន់រវឹករវ៉ក់មិនបេះនៅនឹង ។

សណ្ឋាន : បែបបទ, រាងរៅ, សភាព ។

អវយវៈ : : គ្រឿងប្រដាប់របស់រូបកាយមនុស្ស ។

អធិបតី : ជាធំលើគេ, ជានាយចៅហ្វាយគេ ។

សរីរយន្ត : គ្រឿងបក្រនៃរូបរាងកាយ ។

ស្តីការ . ត្រួតត្រាការ, ចាត់ចែងការ ។

១- អក្ខរាវិរុទ្ធ

ខ្វះ (សរសេរមានរ នៅចុង)

ទំហំ (សរសេរ ទ ស្រះអំនិងហស្រះអំ)

គរគោក (ត្រូវមានរមួយពីមុខ គ)

ម៉ដ្ឋ (ប្រយ័ត្នកុំសរសេរ ម៉ត់)

អវយវៈ (មានយុគលពិន្ទុតែពីមុខ វ ចុងបង្អស់)

និមួយ ៗ ឬនីមួយ ៗ (ដាក់បានទាំងពីរបែប)

វិរឹក (សរសេរ វ មានរ, វ ស្រះអឹនិងក)

ផ្ដេសផ្ដាស (កុំសរសេរផ្ដះផ្ដាស់)

គ-ពាក្យសព្ទ

ទន់ គុ. (ដីត្រង់នេះទន់ណាស់ព្រោះត្រូវទឹក)

ទាន់ កិ.វិ. (គេរត់ដេញទាន់ចោរ)

ទន្ត ន. (លោកគ្រូបាក់ព្រះទន្តអស់ហើយ)

ទ័ណ្ឌ ន. (យក្សគ្រវីទ័ណ្ឌរួចបោះឡើងទៅ)

ម៉ដ្ឋ គុ. (ម្សៅមីម៉ដ្ឋល្អណាស់)

ម៉ត់ កិ.វិ. (ឆ្កែស៊ីម៉ត់ឈាប់ជ្រូកលើជ្រុំ៣)

ហ្មត់ ប្តូមត់ (ធ្វើចិត្តហ្មត់ចត់ឲ្យហ្មត់ហ្មង)

---

## ៣១–ទេសភាពមាត់សមុទ្រ

រស្មីព្រះសុរិយារសៀលម៉ោងបួន កំពុងបណ្តើររន្ទះពេជ្ររលិប ៗ ភ្លេត ៗ លើផ្ទៃជលសា ឯនាយសមុទ្រជាប់ទីនជើងមេឃឯនោះ ៗ បន្ទាប់មកគឺផ្ទាំងសំពត់ផាមួងកទាដែលខៀវស្រងាត់ ហើយដែលយូរ ៗ គេឃើញមានភ្លើងពិលសស្គុះចាំងភ្លែត ៗ ចេញពីផ្ទាំងសំពត់ព្រៃនោះម្តង ៗ ៗនេះហើយគឺរលកបែកផ្កាត្រែង កើតឡើងពីការប៉ះទង្គិចរវាងដុំរលកនឹងដុំសិលាដែលដុះកណ្តាលសមុទ្រ បណ្តាលឲ្យបែកទឹកខ្ចាយសំពោងមើលទៅឃើញសស្គុះ ហាក់បីដូចជាផ្កាត្រែង ៗ

កោះតាយ ឬ កោះទន្សាយពន់ខ្ចីកំប៉ុកដែលនៅខាងត្បូង មើលទៅឃើញយ៉ាងច្បាស់ជិតបង្កើយ ។ ព្រះអាទិត្យបេះ តែថយរស្មីផាលំផាច់ ។ ខ្យល់ដំនោរក៏ចាប់ផ្ដើមប្រគំត្រូវត្រូ ហ៊ូៗ មិនដាច់សូរ ។ ដើមដូនចពា្ល្យដើមស្រោនស្រីនក៏ ទន់ទោរទៅកាន់មាត់ទឹក រលាស់តែចុងធាងទងចុងស្លឹករវិច ៗ ហាក់ដូចជាកំ ។ ឯរលកនៅតែប្រឆាំងទងផ្ទុំសិលាក្រោម ជើងទេរ ឮសូរឆារ ៗ ជានិច្ច ។

អ៊ុម-ឈូផេត

ក- ពន្យល់ពាក្យ

ប្រគំត្រូវត្រូ: លេងភ្លេង, លេងបញ្ចេញសូរភ្លេង ។

ជើងទេរ: ដីប្រាំងដែលជម្រាលនៅមាត់ទឹក ។

ផាមួងកកា : ឈ្មោះពណ៌ខៀវក្រមៅស្មើរបៃតង ។

រសិបៗ : ដែលរញ្ជួបរញ្ជួលឮសូរស្រិបៗ ។

ផ្ទៃជលសា : ផ្ទៃទឹក, ផ្ទៃសមុទ្រ ។

ខ-អក្ខរាវិរុទ្ធ

ស្រងាត់ (អ. ថ ស្រង៉ាត់)

ច្បាស់ (ប្រយ័ត្នកុំសរសេរ ច្បាះ ឬ ច្បះ)

ដំនោរ (មាន រ នៅខាងចុង)

ផ្ដើម (កុំសរសេរ ប្ដើម)

ត្បូតទ្រ្ដី ឬ ដ្បូដទ្រ្ដី (សរសេរបានទាំងពីរយ៉ាង)

បញ្ឈរ (សរសេរញជើងឈ ទឹង រ)

ទេរ (មាន រ នៅចុង)

គ- ពាក្យស័ព្ទ

ពេជ្រ ន. (ស្ត្រីម្នាក់ពាក់បណ្ដោងពេជ្រ)

ពេចន៍ ប. (ពាក្យពេចន៍ក្នុងនេះល្អគ្រាន់បើ)

រលក ន. (រលកទឹកបោកដានខ្ទប)

លលក ន. (លលកយំឆ្លើយឆ្លងគ្នា)

ខុស គុ. ( ដើមត្រុំជ្រុះនៅដីជើងទេវ )

ខុ (ខ្ញុំមិនយល់ទេរឿងនេះ)

ចាំង កិ. ( ព្រះអាទិត្យចាំងរស្មីយ៉ាងខ្លាំង )

ចាំង កិ. ( ផាងឈើកំពុងចាំងសសរ )

ចាំង ន. ( គេធ្វើនំចាំងបានបីចង្កោម )

---

## ៣២ – ការបាកបោលក្រុងអង្គរ

កាលពីដើមសតវត្សទី ១៥ ព្រះអតីតមហាក្សត្រខ្មែរ ព្រះនាមស្រីសុរិយោពណ៌ទី ២ ហៅពញាយ៉ាត បានទ្រង់ព្រះតំរិះ លើករាជធានីពីក្រុងអង្គរមកតាំងនៅទន្លេចតុមុខវិញ ។ បានជាទ្រង់សព្វព្រះរាជហឫទ័យលើកទីក្រុងនេះ ដោយព្រះអង្គទ្រង់ឈ្វេងយល់ថា ទីក្រុងចាស់ស្ថិតនៅក្បែរប្រទេសសៀម

ដែលបច្ចាមិត្រសម័យនោះពេកណាស់ ។ ប្រសិនជាកើតចម្បាំងពាំងដល់ទៀង យើងពិបាកនឹងចាត់ការទប់ទល់ការពារជាពន់ពេក ។

ថ្ងៃមួយ ដែលក្រុមហោរាបានសន្មតទុកជាពេលប្រកបដោយនក្ខត្តឫក្សជោគជ័យសិរីមង្គល , ព្រះរាជា មួយអង្គ ដោយរាជបរិពារ បានយាងចុះគង់លើព្រះទីនាំងនាវាចេញចាកទីក្រុងចាស់ ប្រកបដោយទឹកព្រះទ័យអាឡោះអាល័យក្រៃលែង ។ ក្បួនដង្ហែព្រះនរបតីបានលៀនសន្សឹមៗ កាត់ទន្លេសាប សឹងមានទូកអុំប្រទ័ក្សិណ ស្រែកជយោថ្វាយជ័យឮកងរំពងផង ។

យើងគួរចាំថា គឺព្រះបាទចៅពញាយ៉ាតនេះហើយ ដែលទ្រង់លើកទីក្រុងមកតាំងនៅទន្លេចតុមុខជាដំបូងបំផុត ។

លី-ធាមតេង

7



ក— ពន្យល់ពាក្យ

សតវត្ស : រយៈកាល ១០០ ឆ្នាំ (Siècle) ។

អតីតមហាក្សត្រ : ស្ដេចជាន់មុន, ព្រះរាជាជាន់ដើម ។

ទន្លេចតុមុខ : ទន្លេបួនមុខ ។

បច្ចាមិត្រ : មិនមែនជាមិត្ត, សត្រូវ ។

នក្ខត្តឫក្ស : ថ្ងៃដែលប្រកបដោយកំឡាំងផ្កាយ ។

រាជបរិពារ : រាជបរិវារ, ពួកពលរបស់ក្សត្រ ។

ព្រះទីនាំងនាវា ; ជំនិះទូករបស់ក្សត្រ ។

១- អក្ខរាវិរុទ្ធ

ចតុមុខ ឬ ចតុម្មុខ (ដាក់បានទាំងពីរយ៉ាង)

ហឫទ័យ ឬ ហ្ឫទ័យ (ដាក់បានពីរបែប)

ក្បែរ (សរសេរមាន រ នៅចុង)

ការពារ (កាមាន រ , ពាមាន រ )

ក្រុម ឬ ក្រុំ (ប្រយ័ត្នកុំសរសេរ ក្រំ ឬ ក្រុំម)

សន្ទូត (ឥតមាន រស្យស្រញ្ញាទេ)

នរបតី (អ.ថ.នរប់ប៉ដី)

គ- ពាក្យស័ព្ទ

សព្វ (សព្វថ្ងៃ, សព្វព្រះរាជហឫទ័យ)

សព ន.(គេដុតសពលើជើងក្ករ)

សប់ កិ.(គេសប់កង់ឡានឲ្យប៉ោង)

ផល់ កិ.(ផល់ជើងនឹងថ្ម, ចម្បាំងរាំងផល់)

ផល ន.(ផលនេត្រហូរហៀរពេញភក្ត្រា)

---

## ៣៣- កសិករនិងបុត្រ

ក្រោយដែលជំងឺជាទម្ងន់នាំដល់នូវមរណកាលក្នុងពេលឆាប់ៗ ខាងមុខនេះហើយ កសិករចាស់ម្នាក់បានហៅកូនមកជុំគ្នា រួចផ្តាំថា៖ បើឥតអំពីឪពុកទៅ ដីស្រែជាកេរ្តិ៍ដែល

ឪពុកទុកឲ្យទាំងប៉ុន្មានឯងមិនត្រូវលក់ទេ ដ្បិតក្នុងដីនេះមានកំណប់ដ៏មានថ្លៃជាច្រើន ។ ផ្ដាំប្រកសិករផងក៏ទំលាយខ្លួនទៅកាន់បរលោកទៅ ។

កូនទាំងអស់ បងចាំនូវពាក្យបណ្ដាំរបស់ឪពុក ក៏បបួលគ្នាកាន់ចបកាប់, ចបជីក, ចបចែល តម្រង់ទៅកាន់ដីស្រែ ហើយកាប់គាស់ជីកជ្រួយស្រុសសាយសឹងតែគ្មានបន្ទោះ ដើម្បីរកកំណប់ដ៏មានថ្លៃដែលឪពុកប្រាប់នោះ ៗ ទោះជាប្រឹងកាប់គាស់ត្រាតែសាយសព្វយ៉ាងណា ក៏ពុំប្រទះនឹងកំណប់សោះ, ទាល់ប្រាជ្ញាអស់សង្ឃឹមក៏នាំគ្នាលីចបនឹងប្រដាប់ប្រដាត្រឡប់មកកាន់លំនៅរៀងខ្លួនវិញ ៗ

លុះដើមឆ្នាំ ភ្លៀងចុះកាលណា បុត្រកុដុម្ពិក នាំគ្នាចាប់ប្រកបការកសិកម្មតាមធម្មតាតែសព្វខ្លួន ៗ ដល់ចុងឆ្នាំកាលណា ស្រូវបានផលពេញជម្រុក លក់បានប្រាក់ច្រើនក្រាស់ក្រៃ ទើបដឹងខ្លួនថា៖ បណ្ដាំឪពុកមិន

ខុសទេ ។ គាត់ជាព្រឹទ្ធាចារ្យបានពោលពាក្យជាអាថ៌ប្រស្នាទុកឲ្យកូនដោះស្រាយជាក្រោយ ។

លំ - ដាមតេង

ក- ពន្យល់ពាក្យ

មរណកាល : ពេលស្លាប់, កាលវេលាអស់ជីវិត ។

កសិករ : អ្នកគួរពេស់, អ្នកធ្វើស្រែចំការ ។

ទំលាយខន្ធ : ផុតអាយុ, អស់សង្ខារ ។

បរលោក : លោកដទៃ, ភពដទៃ ។

កសិកម្ម : ការងារគួរពេស់, កិច្ចការអ្នកស្រែ ។

ព្រឹទ្ធាចារ្យ : គ្រូពីបុរាណ, គ្រូជាន់ចាស់ ។

អាថ៌ប្រស្នា : ពាក្យសំពប់ដោះស្រាយដំមានជម្រៅ ។

ខ- អក្ខរាវិរុទ្ធ

មរណកាល (អ.ថ. មរណៈកាល)

គីតា (សរសេរ គ ជើង ន)

ដម្លៃ ឬ តម្លៃ ឬ ដំឡៃ (ដាក់បានដូចគ្នា)

សន្សឹម (សរសេរដើរយស្រៈ អឹ)

ប្រដាប់ប្រដា (គ្មានរនៅចុងទេ)

គ្រាស់គ្រៃ (គ្រាស់សរសេរ ស មានរស្រស្រញា)

អាថ៌ (សរសេរ ថ មានរបាទពីលើ)

គ. វាក្យស័ព្ទ

ដោះ កិ. (បញ្ហានេះត្រូវតែដោះស្រាយ)

ដោះ កិ. (ពួកចោរដោះប្លន់ព្រៃអស់)

ដោះ ន. (កូនក្មេងកំពុងបៅដោះ)

ដស់ កិ. (គេដស់ជាយចេញពីក្នុងផ្ទាំង)

---

## ៣៤- ក្ងាក់ភ្លើង

ក្ងាក់ភ្លើងមានសភាពទ្រង់ទ្រាយដូចក្ងាធម្មតាដែរ តែមានប្រហោងខាងកន្ទុះចេញទៅកំពូល ដែលគេហៅថារន្ធក្ងាក់ភ្លើង ។ រន្ធនេះមានជម្រៅរហូតដល់ផ្ចិតសូលផែនដី ។

កាលណាដល់វេលាភ្នំនឹងចាប់ផ្ទុះ ផ្សែងដែលមានហុយចេញពីកណ្ដាលភ្នំយូរមកហើយនោះ វិនាសលែងមានហុយ ៗ ខណៈនោះ បរិវេណដីជិតភ្នំចាប់រញ្ជួយ គេឃើញផេះនិងវត្ថុរាវដូចបបរ ផុះចេញតាមមាត់រន្ធពីក្នុងដីមកពាសពេញខាងក្រៅ ៗ វត្ថុរាវនេះក្ដៅមហិមា ហូរចុះទៅទីវាលដូចជាស្ទឹងព្រែកនានា ហើយវត្ថុនេះឲ្យគ្រោះថ្នាក់ជាច្រើន កាលបើហូរទៅប៉ះរបស់អ្វី ឬភូមិស្រុក បណ្ដាលឲ្យរលាយខ្យុរ ៗ

វេលាយប់ វត្ថុរលាយនេះបញ្ចេញពន្លឺក្រហមឆ្អៅដូចដុំដែកកំពុងឆេះ ៗ លុះយូរមក កាលបើបាត់ក្ដៅ វត្ថុរាវក៏ត្រជាក់កកកើតបានជាថ្មមានពណ៌ខ្មៅល្អជាច្រើន ៗ

ពិតមែនតែភ្នំភ្លើងបង្កើតគ្រោះថ្នាក់ តែមានឲ្យប្រយោជន៍ច្រើនដែរ ក្រោយពេលដែលរលត់ត្រជាក់ទៅ ៗ គេនាំគ្នា

ទៅភាប់គាស់រកវត្ថុធាតុដើម ដ៏មានតម្លៃដូចជាលោហធាតុ មានមាសជាដើម ។

ណង.ហាប់អាន

ក-ពន្យល់ពាក្យ

វត្ថុធាតុ : គ្រឿងប្រដាប់សំរាប់ធ្វើ, (Elément) ។

លោហធាតុ : ជាតិរឹងកើតពីក្នុងដីមានមាសជាដើម ។

១- អក្ខរាវិរុទ្ធ

ផ្ទិត (ប្រយ័ត្នកុំសរសេរ ផ្សិត)

រន្ធ (កុំសរសេរ រន់ ឬ ពន់)

ខណៈនោះ (មានយុគលពិន្ទុនៅមុខណ)

ផេះ (កុំសរសេរ ផេស)

ខ្សែ (អ.ថ. ខ្សល តែសរសេរ ខ នៅចុង)

www.khmerbooks.fr

លោហធាតុ (អ.ថ. លោហៈធាតុ)

មាស (ប្រយ័ត្ន កុំសរសេរ មាស់)

គ-ពាក្យសព្ទ

ព្រាយ ប.( មានទ្រង់ព្រាយដូចភ្នំចម្ការ )

ព្រាយ ន.( សត្វព្រាយរត់កាត់ព្រៃ)

វេទ ន.(ស្រមោចដឹកស្បៀងចំណីដាក់ក្នុងរន្ធ)

ពាន់ គុ.(ធ្វើការកុំពាន់ពេក)

ប៉ះ កិ.(គេដើរប៉ះគ្នា )

ប៉ាស កិ.( ដាក់ប៉ាសកងឡាន )

ពិត គុ.( ការនេះទុកជាការពិត)

ពិត កិ.(ពិតខ្នងនឹងជញ្ជាំង )

ពិត ន.(មិនកាន់ពិតសរសេរអក្សរ)

ពិធ ន,(ត្រីពិធសម្បត្តិ)

# ៣៥_ឆ្នេរជិលសា

ទេសភាពប្រែគេទយ៉ាងជាក់ស្តែង សន្ទឹកព្រឹក្សយ៉ាង ស្ងុកស្ងួតហើយខៀវស្រស់ គ្របដណ្តប់ជុំជិតទីដីវាលទីង គម្លាតគុម្ពទាំងអស់ មានតែទីដីស្រអំចិលប៉ុណ្ណោះទេ ដែល មើលទៅឃើញក្រហមស្រគាំ ៗ ណាយទឹងផ្កាំងទឹកប្រៃដែល សស្គុះនោះ ៗ ជ្រុកអំបិល មើលទៅឃើញរគេគរកូត ដាច់ ៗ ពីគ្នា ។

នេះហើយ ជាភូមិភាគកំពត ។ នៅចន្លោះកណ្តាល នៃទេសភាពទាំងសងខាង ដែលខៀវស្រស់នោះ ជន មាត់ចាក់កៅស៊ូត្រង់ទីងរន្ទះព្រះសុរិយា មើលទៅឃើញស ស្កុងដូចជាកម្រាលព្រាក់ ណាតសន្ធឹងតម្រង់ទៅរកគុម្ពណាផ្ទៃ មេឃ ដែលសន្ធឹងស្កុកស្តុំនៅខាងមុខ ។ រថយន្តគ្មាន រលាក់សោះ មានតែហើបឡើង ឬ បន្ទាបចុះតាមលំអាន ខ្ពស់ទាប ៗ ហើយបត់បែនទៅតាមបង្កេះភ្នំ ។

រថយន្តចុះអំពីលើភ្នំបន្តិចម្ដងៗ ងាកខាងឆ្វេងហើយសសៀរយឺតៗ ទៅតាមឆ្នេរសមុទ្រដែលនៅជាប់នឹងជើងភ្នំ ។ នេះឯង កែបឆ្នេរផលសា របស់ប្រទេសខ្មែរ ។

អ៊ុម - ឈួរដេត

ក–ពន្យល់ពាក្យ

ឆ្នេរផលសា : មាត់សមុទ្រ (ទីនេះ) (Plage) ។

កម្រាលប្រាក់ : ផ្លូវក្រាលដីស្អាតគេង ។

តាមលំអាន : តាមលំដាប់លំដោយ ។

១- អក្ខរាវិរុទ្ធ

ភេទ (សរសេរប្រកបនឹង ទ)

ស្ដុកស្ដម្ភ (សរសេរ ម ជើង ភ នៅចុង)

គម្ពោធ (ប្រយ័ត្នកុំសរសេរ កំពោធ ឬ កំប៉ូត)

ស្រគាំ (កុំសរសេរស្រគំ)

សនិធាន (កុំសរសេរត្រួតលើគ្នាជាសន្និធាន)

សសៀ (ឥតមាន រ ទេ)

ស្នេរ (មាន រ នៅចុង)

សមុទ្រ ឬ សមុទ្ទ (ដាក់បានពីរយ៉ាង)

គ- ពាក្យស័ព្ទ

រាំង កិ. (ដើមឈើបាក់មករាំងផ្លូវ)

រាំង ន. (ដើមរាំងដុះកណ្ដាលស្រះ)

បត់ កិ. (រថយន្តបត់ទៅខាងលិច)

បទ ន. (គេច្រៀងបទនគររាជ)

---

[illegible] ?

[illegible]

[illegible]

[illegible]

[illegible]

[illegible] - [illegible]

[illegible] Grippe

[illegible] Fièvre

[illegible] Dysenterie

តម្លៃ២០រ,០០